គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល)

Committee For Free And Fair Elections in Cambodia (COMFREL)

# សេចក្តីព្រាង

# របាយការណ៍សង្ខេប ស្តីពី
# ភាពមិនប្រក្រតីនយោបាយ៖

## ការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ និង
## ពុករលួយទាក់ទិននឹងនយោបាយ

កុម្ភៈ ២០១៥

# មាតិកា


១. សេចក្តីផ្តើម ........ 1

២. បទបញ្ញត្តិក្នុងការប្រើប្រាស់ធនធានរដ្ឋ ........ 2

៣. បទបញ្ញត្តិទាក់ទងនឹងអំពើពុករលួយ ........ 3

៤. ទំហំ និងក្របខណ្ឌនៃការប្រើប្រាស់ពាក្យក្នុងរបាយការណ៍ ........ 6

៥. ការរកឃើញ ........ 8

៥.១. ការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ ........ 9

៥.១.១. ភាពមិនត្រឹមត្រូវនៃប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ........ 10

៥.១.២. តម្លាភាពនៃការថវិការដ្ឋ ........ 10

៥.២. អំពើពុករលួយទាក់ទងនឹងនយោបាយ ........ 14

៥.២.១. ការរំលោភអំណាច ........ 15

៥.២.២. តំណែងសម្រាប់សាច់ញាតិ ខ្សែស្រឡាយនិយម (Nepotism, Cronyism) និងទំនាស់ផលប្រយោជន៍ (Conflict of Interest) ........ 17

៥.២.៣. ភាពមិនប្រក្រតីសំណូក និងការកិបកេងដោយមន្ត្រីនយោបាយ ........ 20

៥.២.៤.ភាពមិនប្រក្រតីសំណូក និងការកិបកេងដោយមន្ត្រីសាធារណៈក្នុងតំណែង ........ 22

៥.៣. គ្មានតម្លាភាពនៃទ្រព្យសម្បត្តិ និងហិរញ្ញវត្ថុរបស់គណបក្សសំខាន់ៗ ........ 25

៦. សន្និដ្ឋាន និងអនុសាសន៍ ........ 26

របាយការណ៍អំពីការប្រើប្រាស់ធនធានរដ្ឋ និងអំពើពុករលួយទាក់ទងនឹងនយោបាយ គឺនិយាយសំដៅទៅដល់ការសង្កេត និងការចងក្រងព័ត៌មាន ទាក់ទងនឹងការប្រើប្រាស់ធនធានរដ្ឋ ដើម្បីផលប្រយោជន៍នយោបាយ និងការប្រព្រឹត្តិអំពើពុករលួយដោយមន្ត្រីនយោបាយ និងមន្ត្រីសាធារណៈពាក់ព័ន្ធកិច្ចការនយោបាយ។ របាយការណ៍នេះត្រូវបានចងក្រង តាមរចនាសម្ព័ន្ធដូចខាងក្រោមៈ

## ១. សេចក្តីផ្តើម

នៅឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ ចំណុះឲ្យទីស្តីការគណៈរដ្ឋមន្ត្រី។ បន្ទាប់ពីអនុម័តច្បាប់ប្រឆាំងអំពើ ពុករលួយនៅឆ្នាំ២០១០ អង្គភាពប្រឆាំងអំពើពុករលួយ ត្រូវបានដាក់ឲ្យនៅក្រោមនាយករដ្ឋមន្ត្រី។

រាជរដ្ឋាភិបាលកម្ពុជា ក្នុងនីតិកាលទី៥នៃរដ្ឋសភា ក៏បានលើកឡើងនូវយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ បានបន្តបេសកកម្ម ដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយ ការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ច គឺជាកត្តាដ៏សំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកកំពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ។

រដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិ ស្តីពីការប្រឆាំងអំពើពុករលួយនៅឆ្នាំ២០០៧។ នៅកម្ពុជា យុទ្ធនាការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ត្រូវបានគេមើលឃើញថា នៅមានកំរិតខ្សោយនៅឡើយ ដោយសារតែការចាប់ខ្លួន និងបញ្ជូនខ្លួនទៅតុលាការភាគច្រើនជាមន្ត្រីដែលមានឋានៈតូនាទីតូចតាច។ មន្ត្រីនយោបាយធំៗក្នុងជួររដ្ឋាភិបាល បន្តប្រើប្រាស់ធនធានរដ្ឋ និងប្រព្រឹត្តអំពើពុករលួយទាក់ទិននយោបាយ។

អំពើពុករលួយ នៅក្នុងវិស័យសាធារណៈនៅមានកំរិតខ្ពស់នៅឡើយ។ សន្ទស្សន៍នៃការយល់ឃើញ ស្តីពីអំពើពុករលួយ (CPI) នៃអង្គការតម្លាភាពអន្តរជាតិ នៅឆ្នាំ២០១៤ បានដាក់ចំណាត់ថ្នាក់ឲ្យកម្ពុជានៅលេខរៀងទី១៥៦ ក្នុងចំណោមប្រទេស១៧៥ ដោយទទួលបានពិន្ទុ២១។ លទ្ធផលនេះត្រូវបានគេមើលឃើញថា អំពើពុករលួយនៅតែជាបញ្ហាចំបង ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ដែលស្ទើរតែគ្មានអ្វីដែលប្រជាពលរដ្ឋអាចទទួលបាន ដោយគ្មានការផ្តល់សំណូកឡើយ។

អំពើពុករលួយដែលប៉ះពាល់ជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ អាចបណ្តាលមកពីមូលហេតុនៃពុករលួយទាក់ទងនឹងអ្នកមានអំណាចខាងនយោបាយ។ អំពើពុករលួយខាងនយោបាយបាននិយាយទៅដល់អ្នកមានអំណាចខាងនយោបាយ ប្រើប្រាស់ថវិកាជាតិ ប្រើប្រាស់ធនធានរបស់រដ្ឋ

ប្រព្រឹត្តអំពើពុករលួយ ការរំលោភអំណាច និងការបង្កើតទំនាស់ផលប្រយោជន៍ គ្រួសារនិយម និងបក្សពួកនិយម។

## ២. បទបញ្ញត្តិក្នុងការប្រើប្រាស់ធនធានរដ្ឋ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឲ្យប្រជាពលរដ្ឋកម្ពុជាទាំងអស់មានសិទ្ធិ និងសេរីភាពក្នុងនយោបាយ ដើម្បីចូលរួមក្នុងសង្គម និងកិច្ចការនយោបាយដោយគ្មានដោយការរើសអើង។ ទោះបីយ៉ាងណា ច្បាប់បានកំណត់សិទ្ធិនយោបាយចំពោះក្រុមមួយចំនួនដែលបានផ្តោតច្បាស់ទៅលើមន្ត្រីរបស់រដ្ឋ ដោយមិនរាប់បញ្ចូលមន្ត្រីជាប់ឆ្នោត ឬមន្ត្រីនយោបាយរបស់រដ្ឋាភិបាល។

មន្ត្រីរបស់រដ្ឋ គឺនិយាយសំដៅទៅដល់មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ សមាជិកនៃកងកម្លាំងប្រដាប់អាវុធ និងនគរបាលជាដើម។ ក្រុមទាំងនេះ រួមជាមួយបុព្វ ជិត(ព្រះសង្ឃ) មិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងសកម្មភាពគាំទ្រ ឬប្រឆាំងទៅលើគណបក្ស នយោបាយណាមួយ បើទោះបីជា ក្រុមនេះមានសិទ្ធិក្នុងការបោះឆ្នោត និងជាសមាជិកគណបក្ស នយោបាយណាមួយ ឬអាចចូលរួមជាបេក្ខជនក្នុងការបោះឆ្នោត។ ច្បាប់កម្ពុជាក៏បានហាមឃាត់គណបក្សនយោបាយក្នុងការរៀបចំរចនាសម្ព័ន្ធចាត់តាំងនៅក្នុងស្ថាប័នសាសនា តុលាការ កងកម្លាំងប្រដាប់អាវុធ និងនគរបាលជាតិ។ បើតាមបញ្ញត្តិហាមឃាត់ការប្រើប្រាស់ធនធានរដ្ឋ ជាពិសេសទៅលើការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ក្នុងគោលបំណងបម្រើឲ្យគណបក្សនយោបាយ។

*មាត្រា១៥ នៃច្បាប់ស្តីពីគណបក្សនយោបាយឆ្នាំ១៩៩៧ មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ និងកងកំលាំងនគរបាលជាតិ អាចចូលរួមជាសមាជិកគណបក្សនយោបាយនានាបាន តែមិនត្រូវធ្វើសកម្មភាពគាំទ្រ ឬប្រឆាំងគណបក្សនយោបាលណាមួយឡើយ។ គណបក្សនយោបាយ មិនត្រូវរៀបចំរចនាសម្ព័ន្ធចាត់តាំងក្នុងស្ថាប័ន តុលាការ កងយោពលខេមរភូមិន្ទ និងកងកំលាំងនគរបាលជាតិ។ ជនណាដែលបានប្រព្រឹត្តល្មើស និងវាក្យខ័ណ្ឌទី២នៃមាត្រា១៥នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនមួយលានរៀល។*

*មាត្រា៣៧ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា មន្ត្រីរាជការស៊ីវិលត្រូវមានអព្យាក្រិតភាពក្នុងសកម្មភាពការងារ និងហាមឃាត់ដាច់ខាតនូវការប្រើប្រាស់មុខងាររបស់ខ្លួន និងសម្ភារៈរបស់រដ្ឋដើម្បីបម្រើសកម្ម ភាពនយោបាយដូចខាងក្រោម៖*

- *ធ្វើការដើម្បីផលប្រយោជន៍បេក្ខជននយោបាយ ឬប្រឆាំងនឹងបេក្ខជននយោបាយណាមួយ។*
- *ធ្វើការដើម្បីផលប្រយោជន៍គណបក្សនយោបាយ ឬប្រឆាំងនឹងគណបក្សនយោបាយ*

*ណាមួយ។*

- *ការប្រព្រឹត្តផ្ទុយនឹងមាត្រានេះ ចាត់ទុកជាកំហុស និងការផ្ដាំផ្គងក្នុងវិជ្ជាជីវៈ។*

*មាត្រា៩ នៃច្បាប់ស្ដីពីលក្ខន្តិកៈទូទៅ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ យោធិនមានសិទ្ធិ និងសេរីភាពដូចប្រជាពលរដ្ឋដទៃទៀត។ ក៏ប៉ុន្តែការប្រើសិទ្ធិ និងសេរីភាពខ្លះ ត្រូវមានការកម្រិត ស្របតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់នេះ។ យោធិនត្រូវមានអព្យាក្រឹត្យភាពក្នុងមុខនាទី ក្នុងសកម្មភាពការងារ និងហាមឃាត់ការប្រើមុខងារ និងប្រើប្រាស់សម្ភារៈរបស់រដ្ឋដើម្បីបម្រើសកម្មភាពនយោបាយណាមួយ។*

*ក្រមសីលធម៌សម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទៈ យោធិននៃកងយោធពលខេមរភូមិន្ទគ្រប់រូបត្រូវ៖*

- *ប្រកាន់ខ្ជាប់នូវជំហរអព្យាក្រឹត្យឥតលំអៀងក្នុងមុខនាទី និងក្នុងគ្រប់សកម្មភាពការងារ និងមិនត្រូវយកមុខងារ និងសម្ភារៈរបស់រដ្ឋទៅប្រើប្រាស់ ដើម្បីបម្រើសកម្មភាពនយោបាយគណបក្សណាមួយឡើយ។*

- *ការស្លៀកពាក់ឯកសណ្ឋាន៖ ការស្លៀកពាក់ឯកសណ្ឋានយោធាទៅចូលរួមក្នុងសកម្មភាពឯកជន និងជាសាធារណៈក្នុងការប្រជុំគណបក្សនយោបាយ និងការឃោសនានយោបាយ ត្រូវហាមឃាត់ដាច់ខាត។*

## ៣. បទបញ្ញត្តិទាក់ទងនឹងអំពើពុករលួយ

ក្នុងរបាយការណ៍នេះ អំពើពុករលួយទាក់ទងនឹងនយោបាយ គឺនិយាយសំដៅដល់ការរំលោភអំណាច ខ្សែស្រឡាយ ឬសាច់ញាតិនិយម ទំនាស់ផលប្រយោជន៍របស់មន្ត្រីនយោបាយ ភាពមិនប្រក្រតីនៃសំណូក (សូកប៉ាន់ និងស៊ីសំណូក) ឬកិបកេងដោយមន្ត្រីសាធារណៈក្នុងតំណែងខ្ពស់ ដែលចំណុចទាំងអស់នេះត្រូវបានហាមឃាត់ និងមានចែងក្នុងច្បាប់ ស្ដីពីការប្រឆាំងអំពើពុករលួយ និងបញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

ច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ បានហាមមន្ត្រីរាជការសាធារណៈ និងមន្ត្រីជាប់ឆ្នោតពីបទរំលោភអំណាច ក្នុងការបំពេញមុខងារ ដើម្បីទទួលបានដោយខុសច្បាប់នូវអត្ថប្រយោជន៍ណាមួយ។

*មាត្រា ៣៥ -បទរំលោភអំណាច អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬដោយពលរដ្ឋដែលទទួលអាណត្តិសាធារណៈ តាមការបោះឆ្នោតនៅក្នុងការបំពេញមុខងាររបស់ខ្លួន ចាត់វិធានការ*

*រារាំងការអនុវត្តច្បាប់ ដើម្បីទទួលបានដោយខុសច្បាប់នូវអត្ថប្រយោជន៍ណាមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់៤.០០០.០០០(បួនលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល។ បទល្មើសនេះ ត្រូវ ផ្តន្ទាទោសដាក់ពន្ធនាគារពី៥ (ប្រាំ) ឆ្នាំទៅ១០(ដប់)ឆ្នាំ ប្រសិនបើបទល្មើសនេះមានប្រសិទ្ធភាព។*

នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ក៏បានហាមមន្ត្រីរាជការសាធារណៈ និងមន្ត្រីជាប់ឆ្នោតពីបទស៊ីសំណូក និងបទសូកប៉ាន់។

*មាត្រា ៥៩៤-បទស៊ីសំណូក ត្រូវផ្តន្ទាទោសដាក់ព័ន្ធនាគារពី ៧ (ប្រាំពីរ)ឆ្នាំ ទៅ១៥ (ដប់ប្រាំ)ឆ្នាំ អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬដោយពលរដ្ឋទទួលអាណត្តិសាធារណៈ ដោយការបោះឆ្នោតដែលទទួចសុំ ឬយល់ព្រមទទួលដោយគ្មានសិទ្ធិដោយផ្ទាល់ ឬដោយប្រយោលនូវអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍ណាមួយដើម្បី៖*

*១. បំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬកិច្ចដែលសម្រួលដោយមុខងាររបស់ខ្លួន។*

*២.មិនបំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬកិច្ចដែលសម្រួលដោយមុខងាររបស់ខ្លួន។*

*មាត្រា ៦០៥-បទសូកប៉ាន់ ត្រូវផ្តន្ទាទោសដាក់ព័ន្ធនាគារពី៥ (ប្រាំ)ឆ្នាំ ទៅ១០(ដប់)ឆ្នាំ បុគ្គលណាក៏ដោយ គ្មានសិទ្ធិដោយផ្ទាល់ ឬដោយប្រយោលប្រគល់អំណាច ឬជំនូន ធ្វើការសន្យាណាមួយ ឬផ្តល់អត្ថប្រយោជន៍អ្វីមួយដល់អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈ ដោយការបោះឆ្នោតដែលទទួចសុំ ឬយល់ព្រមទទួល ដោយគ្មានសិទ្ធិដោយផ្ទាល់ ឬដោយប្រយោលនូវអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍ណាមួយដើម្បីឱ្យអ្នករាជការ ឬពលរដ្ឋនោះ៖*

*១. បំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬកិច្ចដែលសម្រួលដោយមុខងាររបស់ខ្លួន។*

*២.មិនបំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬកិច្ចដែលសម្រួលដោយមុខងាររបស់ខ្លួន។*

ទន្ទឹមនឹងនេះ មាត្រា៥៩៧ នៃក្រមព្រហ្មទណ្ឌបានចែងថា *ការកេងយកប្រយោជន៍ដោយខុសច្បាប់ គឺជាអំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬដោយពលរដ្ឋទទួលអាណត្តិ សាធារណៈ ដោយការបោះឆ្នោតដែលទទួលយក ឬរក្សាទុកដោយផ្ទាល់ ឬដោយប្រយោលនូវផលប្រយោជន៍អ្វីមួយនៅក្នុងនោះ៖*

*១.សហគ្រាសណាមួយ ដែលអ្នករាជការ ឬពលរដ្ឋនោះ មានភារកិច្ចរ៉ាប់រងទាំងស្រុង ឬមួយផ្នែកនូវការឃ្លាំតាមដាន ការគ្រប់គ្រង ឬការជម្រះបញ្ជី។*

*២.ប្រតិបត្តិការណាមួយ ដែលអ្នករាជការ ឬពលរដ្ឋនោះមានភារកិច្ចរ៉ាប់រ៉ងទាំងស្រុង ឬមួយផ្នែកនូវការឃ្លាំតាមដាន ឬការទូទាត់។* ហើយមាត្រា៥៩៨ បានចែងអំពី ទោសដែលត្រូវអនុវត្ត *ការកេងយកប្រយោជន៍ដោយខុសច្បាប់ ត្រូវដាក់ពន្ធនាគារពី២ (ពីរ) ឆ្នាំទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់៤.០០០.០០០(បួនលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល។*

មាត្រា ៦០១ បានចែងអំពីបទបំផ្លាញដោយចេតនា និងគៃបំបាត់ដោយទុច្ចរិតរបស់*អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈ ដោយការបោះឆ្នោតដែលគ្រប់គ្រងលិខិតប័ណ្ណមូលនិធិសាធារណៈ មូលនិធិឯកជន ឬវត្ថុអ្វីផ្សេងៗទៀត ដោយសារមុខងាររបស់ខ្លួន ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំ ទៅ១០ (ដប់)ឆ្នាំ ប្រសិនបើអ្នករាជការ ឬពលរដ្ឋនោះបំផ្លាញចោលដោយចេតនា ឬគៃបំបាត់ដោយទុច្ចរិតនូវលិខិត ប័ណ្ណ មូលនិធិសាធារណៈ មូលនិធិឯកជន ឬវត្ថុអ្វីផ្សេងៗទៀតនោះ។*

មាត្រា៥៩២ នៃក្រមព្រហ្មទណ្ឌ បានចែងអំពីនិយមន័យវិតិក្រម *គឺជាអំពើរបស់អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតដែល៖*

*១. ទាមទារ ឬទទួលជាសិទ្ធិ ជាពន្ធ ជាអាករនូវចំនួនប្រាក់ដែលខ្លួនបានដឹងថា មិនត្រូវបង់ ឬដែលលើសពីចំនួនដែលគេត្រូវបង់។*

*២.យល់ព្រម ក្រោមរូបភាពណាមួយ និងដោយមូលហេតុណាមួយក៏ដោយ ធ្វើការលើកឡើង ឬការលោះលាចំពោះការបង់ពន្ធ ឬអាករដែលខ្លួនដឹងថាខុសច្បាប់។* ហើយមាត្រា ៥៩៣ បានចែងពីទោសដែលត្រូវដែលអនុវត្ត *បទវិតិក្រម ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី២ (ពីរ)ឆ្នាំ ទៅ៥ (ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៤.០០០.០០០ (បួនលាន)រៀល ទៅ ១០.០០០.០០០ (ដប់លាន)រៀល។*

មិនត្រឹមតែប៉ុណ្ណោះ រាជរដ្ឋាភិបាលកម្ពុជាបានផ្ដល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៧ ដែលគោលបំណងនៃអនុសញ្ញានេះគឺដើម្បីលើកកម្ពស់ និងពង្រឹងវិធានការដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើពុករលួយកាន់តែមានប្រសិទ្ធភាព និងមានប្រសិទ្ធិភាពលើកកម្ពស់ សម្រួល និងគាំទ្រដល់កិច្ចសហប្រតិបត្តិការអន្តរជាតិ និងជំនួយបច្ចេកទេស ក្នុងការបង្ការ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ រួមទាំងការស្រោចស្រង់ទ្រព្យសម្បត្តិ ដែលបាត់បង់ដោយសារអំពើពុករលួយ និងដើម្បីលើកកម្ពស់សុចរិតភាព គណនេយ្យភាព និងការគ្រប់គ្រងត្រឹមត្រូវនៃកិច្ចការ និងទ្រព្យសម្បត្តិសាធារណៈ។

អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ បានតម្រូវឱ្យរដ្ឋភាគី ត្រូវបង្កើត

ច្បាប់ និងវិធានការផ្សេងៗ ដូចជាករណីដែលពាក់ព័ន្ធនឹងការរំលោភតួនាទី ការគិបកេង/កេងប្រវ័ញ្ច និងការស៊ីសំណូករបស់មន្ត្រីសាធារណៈរបស់រដ្ឋ។ល។

*មាត្រា១៩ ការរំលោភតួនាទី៖ រដ្ឋភាគីត្រូវបង្កើតច្បាប់ និងវិធានការផ្សេងៗ ដែលចាំបាច់ ដោយការប្តេជ្ញាជាសាកល ក្នុងការកំណត់បទល្មើសព្រហ្មទណ្ឌ ដែលពាក់ព័ន្ធនឹងអំពើ ការរំលោភមុខងារ ឬតួនាទី ដូចជាការរំលោភបំពានលើការបំពេញការងារ/មុខងារ ឬ ឬការមិនបានបំពេញមុខងារ ឬតួនាទីឲ្យបានត្រឹមត្រូវ ការប្រព្រឹត្តល្មើសច្បាប់ ដោយមន្ត្រីសាធារណៈណាម្នាក់ ក្នុងខណៈពេលដែលខ្លួនកំពុងកាន់មុខងារ ក្នុងគោលបំណងឆ្លៀតឱកាសកេងចំណេញហួសហេតុ ដើម្បីបម្រើផលប្រយោជន៍ផ្ទាល់ខ្លួន ឬសម្រាប់ជនដទៃ ឬសម្រាប់អង្គភាព។*

*មាត្រា១៧ ការប្រព្រឹត្តទុច្ចរិតដោយការកេងប្រវ័ញ្ច ការប្រព្រឹត្តមិនសមរម្យ ឬការបន្លំបង្វែរទ្រព្យសម្បត្តិ ដោយមន្ត្រីសាធារណៈ រដ្ឋភាគីត្រូវបង្កើតច្បាប់ និងវិធានការផ្សេងៗដែលចាំបាច់ ដោយការប្តេជ្ញាជាសាកល ដើម្បីកំណត់ឲ្យមានបទល្មើសព្រហ្មទណ្ឌ ចំពោះការប្រព្រឹត្តទុច្ចរិតដោយការកេងប្រវ័ញ្ច ការប្រព្រឹត្តមិនសមរម្យ ឬការបន្លំបង្វែរទ្រព្យសម្បត្តិ មូលនិធិ ឬមូលធនប័ត្រ ឬវត្ថុមានតំលៃរបស់បុគ្គលឯកជន ឬសាធារណៈ ដោយមន្ត្រីសាធារណៈណាម្នាក់ ដើម្បីបម្រើផលប្រយោជន៍ផ្ទាល់ខ្លួន បម្រើផលប្រយោជន៍ជនដទៃ ឬអង្គភាពរបស់ខ្លួន ហើយដែលវត្ថុ ឬទ្រព្យសម្បត្តិទាំងនេះ ត្រូវបានគេផ្តល់សេចក្តីទុកចិត្តឲ្យមន្ត្រីសាធារណៈរូបនោះ ក្នុងក្របខណ្ឌនៃការបំពេញតួនាទីរបស់ខ្លួនឲ្យបានត្រឹមត្រូវ។*

*មាត្រា១៥ ការប្រព្រឹត្តស៊ីសំណូករបស់មន្ត្រីសាធារណៈរបស់រដ្ឋ រដ្ឋភាគី ត្រូបង្កើតច្បាប់ រដ្ឋភាគីត្រូវបង្កើតច្បាប់ និងវិធានការផ្សេងៗ ដែលចាំបាច់ ដោយការប្តេជ្ញាជាសាកល ដើម្បីកំណត់ឲ្យមានបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើ (ក) សន្យា ការធ្វើជាអំណោយ ការផ្តល់ឲ្យជាសគុណដល់មន្ត្រីសាធារណៈរូបណាមួយ ទោះបីដោយប្រយោលក្តី ដោយផ្ទាល់ក្តី ក្នុងបំណងទុច្ចរិតដើម្បីទាញផលប្រយោជន៍សម្រាប់ខ្លួនគាត់ជាមន្ត្រីផ្ទាល់ ឬសម្រាប់ជនដទៃ ឬអង្គភាពរបស់ខ្លួន ដោយអំពើទាំងនេះបានញ៉ាំងឲ្យខ្លួនជាមន្ត្រីសាធារណៈ មិនបានបំពេញតួនាទីរបស់ខ្លួន។ (ខ) ការអន្ទងឬការទទួលដោយមន្ត្រីសាធារណៈ ដោយប្រយោលក្តី ឬដោយផ្ទាល់ក្តី ក្នុងគោលបំណងឆ្លៀងឱកាសទាញផលប្រយោជន៍ហួសហេតុ ដើម្បីបម្រើផលប្រយោជន៍ខ្លួនឯងផ្ទាល់ ឬដើម្បីជនដទៃ ឬដើម្បីបម្រើផលប្រយោជន៍អង្គភាពរបស់ខ្លួន ដោយអំពើនេះបានញ៉ាំងឲ្យខ្លួនជាមន្ត្រីសាធារណៈ មិនបានបំពេញតួនាទីរបស់ខ្លួន។*

## ៤. ទំហំ និងក្របខណ្ឌនៃការប្រើប្រាស់ពាក្យក្នុងរបាយការណ៍

អំពើពុករលួយនយោបាយ ត្រូវបានឱ្យនិយមន័យដោយអង្គការតម្លាភាពកម្ពុជាថា ជា "ការគេងបន្លំធនធាន គោលនយោបាយ ធនធានស្ថាប័នរដ្ឋ ដោយអ្នកនយោបាយដែលមានអំណាច

តាមរយៈការរំលោភតួនាទីរបស់ពួកគេ ដើម្បីរក្សាតំណែង និង ពង្រឹងអំណាច ឋានៈ និងទ្រព្យសម្បត្តិរបស់ខ្លួន”។

៤.១.ការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ ដើម្បីបម្រើផលប្រយោជន៍នយោបាយ (Misuse of State Resource for Political Interest)៖ គឺសំដៅបទបញ្ញត្តិ ច្បាប់ដែលបានចែងអំពីការហាមឃាត់ការប្រើប្រាស់សំភារៈឧបករណ៍ អាគារ ធនធានមនុស្ស និងថវិការបស់រដ្ឋដើម្បីផលប្រយោជន៍នយោបាយ (ច្បាប់ស្តីពីគណបក្សនយោបាយ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន និងកងយោធពលខេមរភូមិន្ទ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ)។

៤.២.អំពើពុករលួយទាក់ទងនឹងនយោបាយ៖ គឺសំដៅការរំលោភអំណាច ការប្រើប្រាស់សិទ្ធិអំណាចជាមន្ត្រីនយោបាយ ដើម្បីផលប្រយោជន៍ដល់សាច់ញាតិ និងខ្សែស្រឡាយនិយម (nepotism and cronyism) ការខ្វះតម្លាភាពក្នុងថវិកាជាតិ ភាពមិនប្រក្រតីជាមួយសំណូក និងការកិបកេងដោយមន្ត្រីនយោបាយ និងមន្ត្រីសាធារណៈក្នុងតំណែង ។

៤.២.១.ការរំលោភអំណាច៖ គឺជាការប្រើប្រាស់សិទ្ធិអំណាច និងសមត្ថកិច្ចដោយមន្ត្រីនយោបាយ ឬមន្ត្រីរាជការក្នុងតំណែងលើសពី ឬគ្មានច្បាប់ ឬរំលោភច្បាប់ចែង ដែលប្រឆាំងគោលការណ៍សិទ្ធិមនុស្ស និងប្រជាធិបតេយ្យ ដើម្បីប្រយោជន៍នយោបាយ។

៤.២.២.តំណែងសម្រាប់ខ្សែស្រឡាយ ឬសាច់ញាតិនិយម (cronyism and nepotism)៖ សំដៅលើករណី ការការពារ និងការផ្តល់ផលប្រយោជន៍ដោយលម្អៀងដល់ខ្សែស្រឡាយ សាច់ញាតិបង្កើតដូចជា ម្តាយ ឪពុក បងប្អូន បង្កើត កូន រួមទាំងប្តី ឬប្រពន្ធ ជាពិសេសដែលទទួលបានតំណែង ដោយគ្មានតម្លាភាពក្នុងស្ថាប័នដែលខ្លួនជាមន្ត្រីនយោបាយ ឬមន្ត្រីសាធារណៈក្នុងតំណែង ដឹកនាំ ឬគ្រប់គ្រង។

៤.២.៣.ទំនាស់ផលប្រយោជន៍(conflict of interest) និងវិសមិតភាព(incapability)របស់មន្ត្រីនយោបាយ៖ សំដៅទៅ មន្ត្រីនយោបាយ ដែលបានប្រើប្រាស់ ឥទ្ធិពល និងតួនាទីរបស់ខ្លួនក្នុងការសម្រេចចិត្ត ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ជាខ្សែរស្រឡាយ ឬសាច់ញាតិខ្លួន ឬមន្ត្រីនយោបាយនោះជាសមាជិករដ្ឋាភិបាល។

៤.២.៤.ភាពមិនប្រក្រតីសំណូក(irregularity of giving or gaining bribe and inducement)៖ សំដៅការចោទប្រកាន់ និងទឡ្ហីករណ៍អំពីការស៊ីសំណូក និងសូកប៉ាន់ ឬកិបកេងថវិការដ្ឋដោយមន្ត្រីនយោបាយ និងមន្ត្រីសាធារណៈក្នុងតំណែង។ ករណីភាពមិនប្រក្រតីគឺស្ថិតនៅកម្រិតការចោទប្រកាន់ និងទឡ្ហីករណ៍ដោយបុគ្គលសាធារណៈ ឬអ្នកសារព័ត៌មានដែលទុកជា

ការបាន។

៤.២.៥.មន្ត្រីនយោបាយ សំដៅលើសមាជិករាជរដ្ឋាភិបាល និងសមាជិកមន្ត្រីជាប់ឆ្នោត (មានអាណត្តិតាមការបោះឆ្នោត) ថ្នាក់ជាតិ និងមូលដ្ឋាន។ មន្ត្រីសាធារណៈរបស់រដ្ឋក្នុងតំណែង សំដៅមន្ត្រីមានឋានៈ និងតំណែង ចាប់ពីការិយាល័យរហូតដល់អគ្គនាយក។

ការសង្កេតធ្វើឡើងដោយពឹងផ្អែកទៅលើ ការប្រមូលព័ត៌មានដែលមានស្រាប់ នៅតាមប្រព័ន្ធផ្សព្វផ្សាយ ដោយឡែកសារព័ត៌មាន គេហទំព័ររបស់ស្ថាប័នពាក់ព័ន្ធ ក៏ត្រូវបានប្រើប្រាស់ក្នុងការប្រមូលព័ត៌មានស្តីពីអំពើពុករលួយនយោបាយផងដែរ ដូចជាអង្គភាពប្រឆាំងអំពើពុករលួយ ក្រសួងយុត្តិធម៌ និងគេហទំព័របស់គណបក្សនយោបាយ រួមទាំងរបាយការណ៍របស់អង្គការសង្គមស៊ីវិល។

## ៥. ការរកឃើញ

ការសង្កេតក្នុងកំឡុងពីមករា ដល់ខែវិច្ឆិកា ឆ្នាំរកឃើញយ៉ាងហោចណាស់មាន ២១៧ករណីពុករលួយទាក់ទិននយោបាយ។ ក្រាហ្វិក១ បង្ហាញភាពមិនប្រក្រតីសំណូកដោយមន្ត្រីសាធារណៈក្នុងតំណែងគឺមាន១៣១ករណី ខណៈដែលករណីជាបញ្ហាដែលពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវមាន៦០ករណី ហើយករណីរំលោភអំណាចមាន៣ករណី ករណីពាក់ព័ន្ធនឹងបញ្ហាខ្សែស្រឡាយ សាច់ញាតិនិយមមាន១៨ករណី និងភាពមិនប្រក្រតីសំណូកដោយមន្ត្រីនយោបាយមាន៥ករណី។

**ក្រាហ្វិក១. ចំនួនករណីការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ និងអំពើពុករលួយទាក់ទងនយោបាយ**



## ៥.១. ការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ

ការសង្កេតយកចិត្តទុកដាក់ទៅលើការប្រើប្រាស់ធនធានរដ្ឋ រួមទាំងធនធានមនុស្ស សំភារៈ ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ដើម្បីផលប្រយោជន៍គណបក្សនយោបាយ និងតម្លាភាពនៃថវិកាជាតិ។ មានការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវបម្រើឱ្យគណបក្សនយោបាយចំនួន៦០ករណី បានកត់ត្រាខាងលើក្នុងនោះ គឺជាករណីនៃការប្រើប្រាស់ធនធានមនុស្សរបស់រដ្ឋ ដូចជាការចូលរួមពីសំណាក់កងកម្លាំងប្រដាប់អាវុធ និងមន្ត្រីរាជការស៊ីវិល និងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ក្នុងការធ្វើសកម្មប្រឆាំង ឬគាំទ្រចំពោះគណបក្សនយោបាយ និងថ្នាក់ដឹកនាំគណបក្សផ្សេង។ ការសង្កេតក៏បានរកឃើញថា ការគ្រប់គ្រងថវិកាជាតិគ្មានតម្លាភាព។

ចំនួនករណីនៃភាពមិនប្រក្រតីនៃការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ ក្នុងឆ្នាំ២០១៤នេះ គឺមានការធ្លាក់ចុះ បើប្រៀបធៀបនឹងអំឡុងពេលឃោសនាបោះឆ្នោត ពីខែកញ្ញា ដល់ខែកក្កដា ឆ្នាំ២០១៣កន្លងមក ដែលមាន៣៤៣ ករណី។ សកម្មភាពជួបប្រជុំ ឬកម្មវិធីនានាដែលរៀបចំដោយគណបក្សកាន់អំណាច ក្រោយការបោះឆ្នោត ហាក់ដូចជាមិនសូវមានសកម្មភាពផុលផុស។ រីឯការចូលរួមពីសំណាក់កងកម្លាំងប្រដាប់អាវុធ និងមន្ត្រីរាជការស៊ីវិលក្នុងតំណែងខ្ពស់ពីកម្រិតថ្នាក់ជាតិទៅដល់មូលដ្ឋាន ដូចជាថ្នាក់ដឹកនាំរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ក្នុងសកម្មភាព ឬកម្មវិធីនានាទាំងនោះក៏មិនសូវសកម្មដែរ។

ការថយចុះនៃសកម្មភាពរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធក្នុងតំណែងខ្ពស់ ដើម្បីសកម្មភាពគណបក្សកាន់អំណាច ក្រោយការបោះឆ្នោតឆ្នាំ២០១៣ អាចបណ្តាលមកពីគណបក្សប្រជាជនកម្ពុជា បានបាត់នូវការគាំទ្រយ៉ាងច្រើន ហើយកំពុងពិនិត្យមើលយុទ្ធសាស្ត្រ និងសកម្មភាពរបស់ខ្លួនកន្លងមក ហើយបានដូររូបភាពទៅជាការធ្វើវេទិកាសាធារណៈរៀបចំដោយអាជ្ញាធរ និងរដ្ឋាភិបាលនៅតាមមូលដ្ឋានទៅវិញ។

ការសង្កេតបានបែងចែកការប្រើប្រាស់ធនធានមនុស្សរបស់រដ្ឋ បម្រើឱ្យគណបក្សនយោបាយជាពីរ គឺការចូលរួមធ្វើសកម្មភាពក្នុងថ្ងៃធ្វើការរបស់ខ្លួន និងថ្ងៃឈប់សម្រាករបស់មន្ត្រីសាធារណៈរបស់រដ្ឋក្នុងតំណែងរួមទាំងស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដើម្បីបម្រើសកម្មភាពគណបក្សនយោបាយ ជាពិសេសគណបក្សកាន់អំណាច។ ការសង្កេតរកឃើញថា មាន១៦ករណី ស្មើនឹង៦៧% ជាសកម្មភាពក្នុងថ្ងៃធ្វើការ និងមាន៨ករណី ស្មើនឹង៣៣% ជាសកម្មភាពក្នុងថ្ងៃឈប់សម្រាក។

ករណីខាងលើកើតមាននៅ១០រាជធានី ខេត្ត ដោយឡែកនៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តកំពង់ធំ មានករណីប្រើប្រាស់ធនធានមនុស្សរបស់រដ្ឋ បម្រើឱ្យគណបក្សនយោបាយច្រើនជាងគេ បើប្រៀបធៀបជាមួយខេត្តផ្សេងទៀត។

សកម្មភាពចាត់តាំង និងការប្រព្រឹត្តរបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋាភិបាល ដែលគាំទ្រគណបក្សកាន់អំណាច គឺផ្ទុយពីមាត្រា៣៧នៃច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដែលនិយាយអំពីអព្យាក្រឹត្យភាពរបស់មន្ត្រីរាជការក្នុងសកម្មភាពនយោបាយ និងហាមដាច់ខាតនូវការប្រើប្រាស់មុខងាររបស់ខ្លួន និងសម្ភារៈរបស់រដ្ឋ ដើម្បីបម្រើសកម្មភាពនយោបាយ ដូចជាការធ្វើការដើម្បីផលប្រយោជន៍ដល់បេក្ខជន ឬប្រឆាំងនឹងបេក្ខជននយោបាយណាមួយ និងធ្វើការដើម្បីផលប្រយោជន៍គណបក្សនយោបាយ ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ។

### ៥.១.១. ភាពមិនត្រឹមត្រូវនៃប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ

ប្រព័ន្ធផ្សព្វផ្សាយរដ្ឋ ដោយឡែកទូរទស្សន៍ជាតិកម្ពុជា (ទទក) ត្រូវបានប្រើប្រាស់ដើម្បីគាំទ្រ និងឃោសនាឱ្យគណបក្សប្រជាជនកម្ពុជា ឬឃោសនារិះគន់ប្រឆាំងគណបក្សផ្សេង និងនៅតែបន្តភាពលំអៀងក្នុងការផ្សព្វផ្សាយរបស់ខ្លួន[1]។ នៅឆ្នាំ២០១៤ ចំនួនប្រហែល៩០នៃព័ត៌មានដែលបានសង្កេត គឺបានផ្សព្វផ្សាយសកម្មភាពរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលដែលគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា ហើយ ៧៥% នៃខ្លឹមសារនៃសកម្មភាពទាំងនោះគឺនិយាយគាំទ្រ និងចំណុចល្អរបស់រដ្ឋាភិបាល និងគណបក្សកាន់អំណាច និងមាន២៥% រិះគន់ ឬប្រឆាំងទៅនឹងគណបក្សផ្សេង ជាពិសេសគណបក្សសង្គ្រោះជាតិ។ ថ្នាក់ដឹកនាំរដ្ឋាភិបាលនៃគណបក្សប្រជាជនកម្ពុជា បានផ្សព្វផ្សាយសកម្មភាពខ្លួន តាមរយៈវេទិកាសាធារណៈ ការជួបសំណេះសំណាល និងចែកអំណោយ ការសម្ពោធដាក់ឲ្យប្រើប្រាស់សមិទ្ធផល ការប្រកាសផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង ញត្តិគាំទ្រ និងសេចក្តីប្រកាសព័ត៌មានរបស់ក្រសួង ស្ថាប័នរដ្ឋជាដើម។ ការសង្កេតរកឃើញថា ថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា បានប្រើប្រាស់សកម្មភាព ឬកម្មវិធីទាំងនេះវាយប្រហារ រិះគន់ និងចោទប្រកាន់គណបក្សប្រឆាំង ដើម្បីជាគុណប្រយោជន៍នយោបាយសម្រាប់គណបក្សរបស់ខ្លួន។ ជាក់ស្តែង សេចក្តីប្រកាសព័ត៌មានរបស់រាជធានីភ្នំពេញថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៤ បានចោទប្រកាន់គណបក្សសង្គ្រោះជាតិថា បានញុះញង់ អុចអាល អូសទាញកម្មករឲ្យចូលរួមបាតុកម្មនៅផ្លូវវែងស្រែង កាលពីថ្ងៃទី០២-០៣ ខែមករា ឆ្នាំ២០១៤ ដែលឈានដល់ការប៉ះទង្គិច រវាងកងកម្លាំងសមត្ថកិច្ច និងបាតុករ បណ្តាលអ្នកមានអ្នករបួស និងចាប់ខ្លួន។

### ៥.១.២. តម្លាភាពនៃការថវិការដ្ឋ

ស្ថានភាពតម្លាភាពនៃការគ្រប់គ្រងថវិកានៅកម្ពុជា គឺនៅមានកម្រិតទាបជាខ្លាំងនៅឡើយ[2]។ រាជរដ្ឋាភិបាលកម្ពុជាមិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់ដល់សាធារណជន ហើយនឹងសមាជិកនៃ

---

[1] របាយការណ៍ខុមហ្វ្រែលៈ ប្រជាធិបតេយ្យ ការបោះឆ្នោត និងកំណែទម្រង់ ២០១១ ភ្នំពេញ ខែមីនា ឆ្នាំ២០១២។

[2] Open Budget Survey 2012, ព្រឹត្តិប័ត្រសង្ខេបអំពីតម្លាភាពថវិកា លេខ០៤/ខែមករា ឆ្នាំ២០១២។

រដ្ឋសភាជាតិ អំពីថវិកាជាតិ និងសកម្មភាពហិរញ្ញវត្ថុរបស់ខ្លួននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ កត្តានេះបង្កការលំបាកដល់ប្រជាពលរដ្ឋ និងរដ្ឋសភាក្នុងការតាមដានការចាយវាយរបស់រាជរដ្ឋាភិបាល និងការទាមទារឱ្យរាជរដ្ឋាភិបាលទទួលខុសត្រូវ ចំពោះការគ្រប់គ្រងប្រាក់កាសសាធារណៈរបស់ខ្លួនដែលរួមមាន ការប្រមូលចំណូល និងការប្រើប្រាស់មូលនិធិសាធារណៈនានាប្រកបដោយប្រសិទ្ធភាព។ បើយោងតាមកំណត់សំគាល់របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បានបង្ហាញថា មានតែម្តងប៉ុណ្ណោះ គឺនៅឆ្នាំ២០១១ ដែលរាជរដ្ឋាភិបាលកម្ពុជា បានផ្តល់សេចក្តីព្រាងច្បាប់ថវិកាជាតិដល់សង្គមស៊ីវិលដើម្បីពិនិត្យឡើងវិញ។ ចាប់ពីពេលនោះមកសង្គមស៊ីវិលមិនដែលបានទទួលទៀតឡើយ ហើយជារឿយៗ បញ្ហាពេលវេលាមិនគ្រប់គ្រាន់ជាហេតុផលដែលរាជរដ្ឋាភិបាលបានលើកឡើងក្នុងការរារាំងការចូលរួមរបស់សង្គមស៊ីវិល។[3] ជាក់ស្តែង ច្បាប់ស្តីពីការគ្រប់គ្រងថវិកាជាតិសម្រាប់ឆ្នាំ២០១៥ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ បានអនុម័តដោយតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាតែប៉ុណ្ណោះ ប៉ុន្តែតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិមិនគាំទ្រ។ បញ្ហានេះ គឺបណ្តាលមកពីគ្មានតម្លាភាពនៃសេចក្តីព្រាងច្បាប់ថវិកានេះ។ តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ ជាពិសេស គណៈកម្មការជំនាញរដ្ឋសភាទទួលបន្ទុកហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម មិនបានទទួលរបាយការណ៍ និងឯកសារលំអិតទាក់ទងថវិកាជាតិឆ្នាំ២០១៥នេះ បើទោះបីគណៈកម្មការនេះបានស្នើរដ្ឋាភិបាលឲ្យផ្តល់របាយការណ៍ និងឯកសារបន្ថែមក៏ដោយ។

ករណីគ្មានតម្លាភាពមួយ គឺការគ្រប់គ្រងចំណូលនៃថវិកាជាតិ ដែលបានពីការប្រមូលចំណូលពីការលក់ ការដូរ ឬការជួលទ្រព្យសម្បត្តិរបស់រដ្ឋ រាជរដ្ឋាភិបាលកម្ពុជាក៏មិនបាន ផ្តល់ព័ត៌មានគ្រប់គ្រាន់ ឬរបាយការណ៍ និងការពន្យល់ច្បាស់លាស់ដល់សាធារណជនដែរ។ ក្នុងច្បាប់គ្រប់គ្រងថវិកាជាតិ ចំណូលមិនមែនសារពើពន្ធដែលបានពីការលក់ ការដូរ ឬជួលទ្រព្យសម្បត្តិរបស់រដ្ឋ ជាពិសេសផលនៃសម្បទាន និងការជួលដីធ្លី (ជំពូក៧២ គណនី ៧២០០ និងអនុគណនី៧២០០២ សម្បទានព្រៃឈើ អនុគណនី៧២០០៤ សម្បទានរ៉ែ អនុគណនី៧២០០៥ ការជួលដីទំនេរ និងជំពូក ៧៣ អនុគណនី៧៣០០៣ ផលទុននៃសកម្មភាពទេសចរណ៍ និងអនុគណនី៧៣០០៤ ផលទុននៃសកម្មភាពវប្បធម៌ ឃើញថាមានចំនួនប្រហែលត្រឹមតែ ១៨៦ ពាន់លានរៀល (៤៦លានដុល្លា) ក្នុងឆ្នាំ២០១២ ចំនួនប្រហែល ១៩៧ ពាន់លានរៀល (៤៩លានដុល្លា) ក្នុងឆ្នាំ២០១៣ ចំនួនប្រហែល ៤១៩ពាន់លានរៀល (១០៤ លានដុល្លា) ក្នុងឆ្នាំ២០១៤ និងមានចំនួនប្រហែល ៣៨៩ ពាន់លានរៀល ( ប្រហែល ៩៧ លានដុល្លា) ក្នុងឆ្នាំ២០១៥។ បើប្រៀបធៀបជាមួយតម្លៃពិតប្រាកដលើទីផ្សារ តម្លៃនេះមានភាពខុសគ្នាយ៉ាងសម្បើម។

[3] NGOs Forum, NGOs and Media Call for Detail National Budget Information, 16 October 2014.

| គណនី | អនុគណនី | ប្រភេទទី២៖ ចំណូលមិនមែនសារពើពន្ធ | ច្បាប់ហិរញ្ញវត្ថុ (ឯកតាលានរៀល) | | | |
|---|---|---|---|---|---|---|
| | | | 2012 | 2013 | 2014 | 2015 |
| 7200 | | ផលនៃសម្បទាន និងការជួលដីធ្លី | | | | |
| | 72002 | សម្បទានព្រៃឈើ | 20.700,0 | 20.400,0 | 39.000,0 | 39.545,0 |
| | 72004 | សម្បទានរ៉ែ | 8.853,3 | 10.215,9 | 82.000,0 | 43.747,7 |
| | 72005 | ការជួលដីទំនេរ | 13.085,3 | 13.282,3 | 14.196,7 | 24.206,2 |
| | 73003 | ផលទុននៃសកម្មភាពទេសចរណ៍ | 139.774,7 | 150.065,0 | 270.952,1 | 256.904,5 |
| | 73004 | ផលទុននៃសកម្មភាពវប្បធម៌ | 3.579,5 | 3.810,0 | 13.027,3 | 24.887,9 |
| | | សរុប | 185.992,8 | 197.773,2 | 419.176,1 | 389.291,3 |

ប្រភព៖ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២,២០១៣,២០១៤,២០១៥

ជាឧទាហរណ៍ សំណួរជាច្រើនអំពីការប្រមូលថវិកាទស្សនាប្រាសាទអង្គរវត្ត ក៏ជាបញ្ហាលេចធ្លោ ដែលលើកឡើងដោយតំណាងរាស្ត្រនៃគណបក្សប្រឆាំង។ បើតាមអាជ្ញាធរជាតិអប្សរា ឲ្យដឹងថា ចំណូលបានមកពីការចូលទស្សនាប្រាសាទអង្គរវត្តនៅឆ្នាំ២០១៤ ក្នុងរយៈពេល១០ខែ មានជាង ៤៧ លានដុល្លារ។ ចំណែកនៅក្នុង២០១៣ ចំណូលសរុបពីការលក់សំបុត្រទស្សនា មានទៅដល់ ៥៧.៦ លានដុល្លារ។ គណៈកម្មការទីពីរនៃរដ្ឋសភាទទួលបន្ទុកហិរញ្ញវត្ថុ ធនាគារ និងសវនកម្មបានចុះទៅជួបមន្ត្រីអាជ្ញាធរអប្សរា។

របាយការណ៍របស់អាជ្ញាធរអប្សរាថា មានភ្ញៀវបរទេសចំនួន១លាន៨ សែននាក់ មកលេងប្រាសាទ អង្គរវត្ត ហើយក្នុងអំឡុងរយៈពេល១០ខែក្នុងឆ្នាំ២០១៤ ចំណូលពីការលក់សំបុត្រទស្សនាប្រាសាទអង្គរវត្ត គឺមានចំនួន ៥២ លានដុល្លារ។

លោកសុន ឆ័យ អនុប្រធានគណៈកម្មការហិរញ្ញវត្ថុ ធនាគារ និងសវនកម្មរដ្ឋសភាតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិមិនបានព័ត៌មានលំអិតអំពីចំណូល ចំណាយ និងថវិកាទស្សនាប្រាសាទអង្គរ វត្ត។ ហេតុដូចនេះ មានទំនាស់អំពីពត៌មានចំនួនជើងហោះហើរ ឬការធ្វើដំណើរទៅទស្សនាប្រាសាទអង្គរវត្ត។ តួលេខពីអាជ្ញាធរអប្សរា មានតែ៣៥ភាគរយនៃភ្ញៀវទេសចរទាំងនោះប៉ុណ្ណោះ ដែលបានទៅទស្សនាប្រាសាទអង្គរវត្ត។

យោងតាមលោកសុន ឆ័យ អាជ្ញាធរអប្សរាបានអះអាងប្រាប់លោក សុន ឆ័យ ថា ភ្ញៀវទេសចរចំនួន៥៨ភាគរយ បានទិញសំបុត្រត្រឹមតែតម្លៃ២០ដុល្លារ តែលោក សុន ឆ័យ បានទទួល គឺថាភ្ញៀវទេសចររហូតទៅដល់៦៥ភាគរយបានទិញសំបុត្រប្រភេទ៤០ដុល្លារ។

លោកសុន ឆ័យ រកឃើញថា ចំពោះការប្រគល់ទីតាំងតំបន់អង្គរដ៏ល្បីល្បាញ ទៅឲ្យក្រុម

ហ៊ុន សុខា របស់លោកឧកញ៉ា សុខ គង់ ជាអ្នកប្រមូលប្រាក់ ដោយពុំមានការដេញថ្លៃប្រកួតប្រជែងនោះបានថ្លែងថា កិច្ចការរបស់អាជ្ញាធរអប្សរា គឺពាក់ព័ន្ធនឹងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់។ អាជ្ញាធរអប្សរាបានជួលដីទំហំ២៣ហិកតា នៅក្នុងតំបន់របស់អាជ្ញាធរអប្សរា ទៅឲ្យក្រុមហ៊ុនរបស់លោក សុខ គង់ រួចហើយ ក្នុងតម្លៃ៩,៦លានដុល្លារ ក្នុងរយៈពេល៧០ឆ្នាំ ក្នុងតំបន់ទេសចរដែលតម្លៃដីក្នុងទីផ្សារអាចច្រើនជាង៣ដងនៃតម្លៃខាងលើ។

អាជ្ញាធរអប្សរាបានចេញសេចក្តីប្រកាសព័ត៌មាន ប្រាប់អំពីកិច្ចប្រជុំជាមួយគណៈប្រតិភូនៃគណៈកម្មការហិរញ្ញវត្ថុ និងធនាគារនៃរដ្ឋសភា។ ទោះយ៉ាងណាក្តី អាជ្ញាធរអប្សរាមិនបានផ្តល់តួលេខច្បាស់លាស់ និងការពន្យល់លម្អិតនោះទេ គ្រាន់តែបញ្ជាក់ថា កិច្ចពិភាក្សានៅក្នុងអង្គប្រជុំ គឺដើម្បីដឹងស៊ីជម្រៅអំពីការអភិរក្សអង្គរ ហើយផ្តោតទៅលើប្រធានបទបី រួមមាន ទីមួយ ការជួសជុលប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ ទីពីរ ការអភិវឌ្ឍន៍ និងការរៀបចំរចនាសម្ព័ន្ធ រវាងរមណីយដ្ឋានអង្គរ និងការប្រើប្រាស់ដីក្នុងតំបន់ការពារទីមួយ និងតំបន់ការពារទីពីរ នៃរមណីយដ្ឋានអង្គរ និង ទីបី ការគ្រប់គ្រងចំណូល និងការចំណាយដទៃៗទៀត ដែលអាជ្ញាធរអប្សរាបានទទួល ជាពិសេស ចំណូលទទួលបានពីភ្ញៀវទេសចរដែលចូលទៅទស្សនារមណីយដ្ឋានអង្គរ។ សេចក្តីប្រកាសព័ត៌មាននោះបានឲ្យដឹងថា៖ «ចំពោះករណីនេះ អាជ្ញាធរអប្សរា បានពន្យល់លម្អិតសំរាប់គណៈប្រតិភូនៃគណៈកម្មការហិរញ្ញវត្ថុ ធនាគារ និងសវនកម្មរបស់សភា និងក៏បានផ្តល់ឯកសារនៃការលក់សំបុត្រទស្សនាប្រាសាទអង្គរសម្រាប់ឆ្នាំ២០១០-២០១១- ២០១២- ២០១៣ និងនៅក្នុងរយៈពេល១១ខែនៃឆ្នាំ២០១៤» នេះ។

លើសពីនេះទៅទៀត ករណីធំៗ នៃការ លក់ ជួល ឬ ដោះដូរ ចលន ឬអចលនទ្រព្យរបស់រដ្ឋដែលមិនមានព័ត៌មានអំពីចំណូលទាំងនោះក្នុងថវិកាជាតិ មានដូចជា ដីនៅតំបន់បឹងកក់ ដែលមានផ្ទៃក្រឡា ១៣៣ ហិចតា ដែលរដ្ឋបានជួលទៅឱ្យក្រុមហ៊ុន ស៊ូកាកូ (shukaku Inc) របស់លោក ឧញ៉ា ឡៅ ម៉េងឃិន និងជាសមាជិកព្រឹទ្ធសភា គណបក្សប្រជាជនកម្ពុជារយៈពេល៩៩ឆ្នាំក្នុងតម្លៃ៧៩លានដុល្លារអាមេរិក ដីនៅតំបន់កោះពេជ្រ ៧៥ហិកតា លក់ទៅឱ្យឧកញ៉ា ពង្ស ខៀវសែ ការជួលតំបន់ជុំវិញពិហុកីឡាដ្ឋានជាតិអូឡាំពិក ដីដ៏ធំល្វឹងល្វើយនៅតំបន់បឹងទំពន់។ល។ និងចលនទ្រព្យ ស្ថាប័នរដ្ឋ ដូចជាទីស្នាក់ការក្រសួងជាដើម ឬអចលនទ្រព្យផ្សេងៗទៀត ក្នុងការវិនិយោគធ្វើជាតំបន់អភិវឌ្ឍជាដើម។ល។ តម្លៃទីផ្សារនៃដីក្នុងរាជធានីភ្នំពេញអាចមានតម្លៃខ្ពស់ជាងនេះ ឧទាហរណ៍ដីនៅតំបន់បឹងកក់មានតម្លៃប្រហែល១០លានដុល្លារសហរដ្ឋអាមេរិក ក្នុង១ហិកតានេះបើតាមសេចក្តីជូនដំណឹងរបស់ក្រុមហ៊ុន HLH Group របស់ប្រទេសសឹង្ហបូរី ដែលបានព្រមព្រៀងទិញដីបានទិញដីនៅតំបន់នេះពីក្រុមហ៊ុន Shukaku និងបានបញ្ចប់កិច្ចសន្យាទិញទៅវិញ ក្រោយពីក្រុមហ៊ុនដឹងថាដីនៅតំបន់នេះជាដីទំនាស់ដែលមិនទាន់បានដោះស្រាយព្រមទាំងមានការបណ្តេញចេញប្រជាពលរដ្ឋជាច្រើនគ្រួសារ។ បើយោងតាមតម្លៃព្រមព្រៀងរបស់

ក្រុមហ៊ុនទាំងពីរ ដូច្នេះតំបន់ដែលមានជម្លោះដីរ៉ាំរ៉ៃមួយកន្លែងនេះអាចមានតម្លៃជាង ១ពាន់លានដុល្លារសហរដ្ឋអាមេរិក[4]។

ចំណូលដែលបានមកពីការលក់ ជួល ឬដោះដូរ ប្រជាពលរដ្ឋមិនបានដឹងថា តើទំហំប្រាក់ចំណូល ដែលបានមកពីការជួល ដោះដូរ លក់ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋទាំងនោះ មានទំហំប៉ុណ្ណា? ឬថាប្រាក់ចំណូលរាប់លានដុល្លារទាំងនោះបានដាក់បញ្ចូលទៅក្នុងប្រភេទប្រភពចំណូលណាមួយឲ្យពិតប្រាកដនៃថវិកាជាតិ ហើយក៏គ្មានរបាយការណ៍លម្អិតស្តីពីទំហំប្រាក់ចំណូលទាំងនោះ តាមប្រភពនីមួយឡើយ។ ការស្នើសុំឲ្យការផ្តល់ឯកសាររបាយការណ៍លម្អិត ពីក្រុមអង្គការសង្គមស៊ីវិល ឬពីសមាជិកសភា គឺតែងតែត្រូវបានបដិសេធដោយមន្រ្តីរដ្ឋាភិបាលដោយហេតុផលផ្សេងៗ។

លើសពីនេះទៅទៀត កង្វះតម្លាភាពចំណូលសម្រាប់ថវិកាជាតិ (បន្ទាត់ថវិកា៧៥ និងបន្ទាត់ថវិកា៥០ ដែលបានមកប្រាក់កម្ចី ជំនួយ និងការឧបត្ថម្ភធន) ត្រូវបានអនុវត្តក្រៅរតនាគាជាតិក្នុងឆ្នាំ២០១៤ ប្រហែល៨៦៥ លានដុល្លារសហរដ្ឋអាមេរិក និងប្រហែល៩២១ លានដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ២០១៥។

ទន្ទឹមនឹងនោះ មានការរិះគន់ និងចោទប្រកាន់លើការប្រើប្រាស់ថវិកា ១,៥ពាន់លានដុល្លាអាមេរិក ស្មើនឹង ៤៤ភាគរយនៃថវិកាជាតិសរុប ដែលជាថវិកាចំណាយមិនទាន់បែងចែកក្នុងឆ្នាំ ២០១៤។ វាជាចំនួនទឹកប្រាក់ដ៏ធំ ដែលជាប់មន្ទិលសង្ស័យថាបានប្រើប្រាស់ដោយគ្មានតម្លាភាព អាចជាទ្វារចំហសម្រាប់ភាពមិនប្រក្រតី ការកិបកេង និងប្រើប្រាស់សម្រាប់ផលប្រយោជន៍នយោបាយ។ រដ្ឋាភិបាល ពិសេសក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអះអាងថា ភាគច្រើននៃថវិកាជាតិដែលមិនទាន់បានបែងចែកស្ថិតក្នុងគោលដៅរួចហើយ ដោយថវិកាទាំងនោះ នឹងត្រូវចំណាយលើផ្នែកជាច្រើន ដូចជាហេដ្ឋារចនាសម្ព័ន្ធរួមមានផ្លូវថ្នល់ សាលារៀន និងមន្ទីរពេទ្យ និងបម្រុងទុកសម្រាប់ការឆ្លើយតបបន្ទាន់ចំពោះគ្រោះធម្មជាតិ និងបញ្ហាសន្តិសុខជាតិ។ ដោយឡែកសំណើថវិកាឆ្នាំ ២០១៥ ទុកប្រាក់ចំនួន ៦០៨លានដុល្លារអាមេរិកជាថវិកាគ្មានការបែងចែក។ ទឹកប្រាក់បម្រុងទុកនេះមានការធ្លាក់ចុះជាងឆ្នាំ២០១៤ ប៉ុន្តែទោះបីជាយ៉ាងនេះក្តីវាជាទម្លាប់មិនល្អមួយ ហើយជាមូលហេតុដែលគួរបារម្ភ។

### ៥.២. អំពើពុករលួយទាក់ទងនឹងនយោបាយ

ដូចដែលបានបង្ហាញខាងលើ អំពើពុករលួយទាក់ទងនឹងនយោបាយ គឺសំដៅការរំលោភអំណាច ការប្រើប្រាស់សិទ្ធិអំណាចជាមន្រ្តីនយោបាយ ដើម្បីផលប្រយោជន៍ដល់សាច់ញាតិ និងខ្សែស្រឡាយនិយម ការខ្វះតម្លាភាពក្នុងថវិកាជាតិ ភាពមិនប្រក្រតីជាមួយសំណូក និងការកិប

[4] The CAMBODIA DAILY, JUNE 26, 2014

តែងដោយ មន្ត្រីនយោបាយ ការតិបតែង និងភាពមិនប្រក្រតីសំណូកដោយមន្ត្រីនយោបាយ និងមន្ត្រីសាធារណៈក្នុងតំណែង។

### ៥.២.១. ការរំលោភអំណាច

មានករណីរំលោភអំណាចដោយរដ្ឋាភិបាល និងអាជ្ញាធរ ដើម្បីបំរើផលប្រយោជន៍នយោបាយ ក្នុងនោះមានការចេញ បទបញ្ជាដែលលើសពីច្បាប់កំណត់ ឬគ្មានច្បាប់ចែង។ ជាឧទាហរណ៍ ការចេញសារាចរណែនាំ ស្តីពីបែបបទការងាររបស់គណៈកម្មការនានានៃរដ្ឋសភាចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ ដោយប្រធានរដ្ឋសភា។ ការចេញសារាចរណែនាំនេះ គឺមិនស្របតាមគោលការណ៍ប្រជាធិបតេយ្យ តម្លាភាព ប្រសិទ្ធភាព និងរដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា។

រដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុងសភា និងច្បាប់ណាមួយ មិនមានចែងមាត្រាណាមួយផ្តល់អំណាចឲ្យប្រធានសភាចេញ «សារាចរ ឬបទបញ្ជាឯកត្តភូត» ដើម្បីកំណត់សិទ្ធិអំណាច និងបែបបទការងារផ្ទៃក្នុងរបស់គណៈកម្មការជំនាញនានានៃរដ្ឋសភា។

សារាចរណែនាំរបស់ប្រធានរដ្ឋសភានេះ ដកសិទ្ធិគណៈកម្មការជំនាញរបស់រដ្ឋសភា ដែលចែងថា «គណៈកម្មការពុំត្រូវអញ្ជើញសង្គមស៊ីវិល ឬសាធារណជនមកចូលរួមប្រជុំរបស់ខ្លួនឡើយ»។

សារាចរណែនាំរបស់ប្រធានរដ្ឋសភាបានចែងថា ក្នុងការប្រជុំសុំការបំភ្លឺជុំវិញការអនុវត្តន៍ច្បាប់ គណៈកម្មការពុំត្រូវអញ្ជើញសង្គមស៊ីវិល ឬអ្នកសារព័ត៌មានមកសង្កេតការណ៍ទេ ត្បិតមានតែរដ្ឋមន្ត្រី ឬតំណាងរាជរដ្ឋាភិបាលតែប៉ុណ្ណោះ ដែលមានភារកិច្ចមកបំភ្លឺគណៈកម្មការ។ បន្ទាប់ពីគណបក្សសង្គ្រោះជាតិបានដឹកនាំគណៈកម្មការជំនាញនៃរដ្ឋសភាចំនួន៥ សារាចរនេះមានបំណងរារាំងការចូលរួមសង្កេតការណ៍ ក្នុងការប្រជុំដេញដោលជា «សាធារណៈ» រវាងគណៈកម្មការជំនាញនៃរដ្ឋសភា និងរដ្ឋមន្ត្រី ឬតំណាងរាជរដ្ឋាភិបាល។

ករណីមួយទៀត គឺករណីផ្អាកបណ្តោះអាសន្ន នូវការប្រើប្រាស់ទីលានប្រជាធិបតេយ្យដោយអាជ្ញាធរសាលារាជធានីភ្នំពេញនៅដើមខែមករាឆ្នាំ២០១៤។ គ្មានច្បាប់មួយណាដែលផ្តល់អំណាចឱ្យសាលារាជធានីភ្នំពេញធ្វើការផ្អាកសេរីភាពប្រមូលផ្តុំ និងការធ្វើបាតុកម្មដោយសន្តិវិធីនៅទីលានប្រជាធិបតេយ្យនោះទេ។ អាជ្ញាធរសាលារាជធានីភ្នំពេញបានប្រកាសបិទទីលានប្រជាធិបតេយ្យជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យប្រជាពលរដ្ឋប្រើប្រាស់សំរាប់សំដែងមតិ ចាប់តាំងពីថ្ងៃទី៤ ខែមករា ឆ្នាំ២០១៤ ក្រោមលេសថា សំរាប់ទុកធ្វើការស៊ើបអង្កេត ករណីដែលកងកម្លាំងប្រដាប់អាវុធ រដ្ឋាភិបាលបានប្រើប្រាស់អំពើហឹង្សាទៅលើកម្មករ នៅលើផ្លូវវែងស្រែង និងនៅខាង

មុខរោងចក្រ យ៉ាក់ជីន កាលពីថ្ងៃទី២ និងទី៣ ខែមករា ឆ្នាំ២០១៤ កន្លងមក។

ទីបំផុតនៅថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៤ មន្ត្រីនយោបាយក្រសួងមហាផ្ទៃនៃគណបក្សប្រជាជនកម្ពុជាបានថ្លែងថា បើគណបក្សសង្គ្រោះជាតិចូលរដ្ឋសភានោះ ទីលានប្រជាធិបតេយ្យនឹងត្រូវបានបើកឡើងវិញ។

មានករណី រំលោភបំពានអំណាចដោយការប្រើប្រាស់ឆ្មាំសន្តិសុខក្រៅក្របខណ្ឌ ដោយគ្មានការបណ្តុះបណ្តាលត្រឹមត្រូវដោយអាជ្ញាធររាជធានីភ្នំពេញ ក្នុងការបង្ក្រាបដោយហិង្សាទៅលើក្រុមអ្នកតវ៉ា ខណៈដែលកងកម្លាំងប្រដាប់អាវុធរបស់ជាតិ ត្រូវបានគេប្រើប្រាស់ដើម្បីការពារទ្រព្យសម្បត្តិឯកជន ឬដីរបស់ក្រុមហ៊ុន និងអ្នកមានអំណាច នេះបើយោងតាមរបាយការណ៍របស់អង្គការសិទ្ធិមនុស្ស។

ករណីដាច់ដោយឡែកមួយទៀត គឺពាក់ព័ន្ធការចេញលិខិតរបស់លោក ឡាយ វណ្ណៈ អភិបាលខេត្តតាកែវ ចេញលិខិតកោះហៅប្រធានសាលាដំបូង និងព្រះរាជអាជ្ញាអមសាលាដំបូងឲ្យចូលខ្លួនទៅបំភ្លឺពាក់ព័ន្ធទៅនឹងសំណុំរឿងព្រហ្មទណ្ឌមួយ កាលពីថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ដែលជាទង្វើខុសរដ្ឋធម្មនុញ្ញ និងច្បាប់។ យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែកដាច់ស្រឡះពីគ្នា រវាងអំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ ការចាត់តាំង ឬការដាក់វិន័យ ឬកោះហៅចៅក្រមមកសួរនាំបាន គឺមានតែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតែប៉ុណ្ណោះ។

ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជានាយករដ្ឋមន្ត្រីស្តីទី ក្នុងឱកាសដែលលោកអញ្ជើញចូលរួមប្រជុំបូកសរុបការងារប្រចាំខែវិច្ឆិកា និងលើកទិសដៅការងារខែធ្នូ នាព្រឹកថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៤ នេះនៅក្រសួងមហាផ្ទៃ បានស្តីបន្ទោសទៅលើលោក ឡាយ វណ្ណៈ អភិបាលខេត្តតាកែវ ករណីប្រើប្រាស់កម្លាំងប្រដាប់អាវុធទៅដាក់របាំងរារាំង និងហាមឃាត់ប្រជាពលរដ្ឋ ព្រះសង្ឃ តាជី យាយជី មិនឲ្យដើរហែក្បួនធម្មយាត្រា ដោយចេញដំណើរពីស្រុកគីរីវង្ស ខេត្តតាកែវ ឆ្ពោះមកកាន់រាជធានីភ្នំពេញ ដើម្បីចូលរួមក្នុងទិវាសិទ្ធិមនុស្សអន្តរជាតិ ១០ ធ្នូ កាលពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៤ ថាជា "មន្ត្រីធ្វើការគ្មានដឹងទិសតំបន់ ធ្វើការអត្តនោម័តតែខ្លួនឯង គ្មានសុំយោបល់ថ្នាក់លើ"។ ត្រង់នេះបញ្ជាក់ថា អាជ្ញាធរ និងមន្ត្រីរាជការក្នុងតំណែង មិនបានធ្វើតាមច្បាប់ទេ តែត្រូវស្មើ ឬធ្វើតាមបទបញ្ជារបស់មន្ត្រីនយោបាយថ្នាក់លើ ក្នុងន័យការពារ និងការបំរើផលប្រយោជន៍នយោបាយទៅវិញ។

ដោយសារតែគ្មានបទបញ្ញត្តិនៃច្បាប់ចែងកំណត់អំពីចំនួនក្រសួង សមាជិកគណៈរដ្ឋមន្ត្រី អនុរដ្ឋលេខាធិការ និងទីប្រឹក្សារាជរដ្ឋាភិបាល រាជរដ្ឋាភិបាលនីតិកាលទី៥ ឬ/និងនាយករដ្ឋមន្ត្រីដឹកនាំដោយគណបក្សប្រជាជនកម្ពុជាបានបង្កើត និងបង្កើនក្រសួងដល់ចំនួន២៨ ដោយលុប

អាជ្ញាធរជាតិមួយចំនួន។ ហើយរាជរដ្ឋាភិបាលនេះ នៅតែមានចំនួនច្រើនរហូតដល់ប្រមាណ ៦០០នាក់ ក្នុងនោះសមាជិករាជរដ្ឋាភិបាលមានចំនួន២៤៤រូប និង អនុរដ្ឋលេខាធិការមានចំនួន ២៣៨ រូប ព្រមទាំងទីប្រឹក្សារាជរដ្ឋាភិបាលចំនួនប្រមាណជាង ២០០រូប និងមន្ត្រីនយោបាយជាន់ខ្ពស់ច្រើនរូបទៀតផង។ ចំនួនសមាជិករដ្ឋាភិបាលដ៏ធំបែបនេះត្រូវបានប្រើប្រាស់ដើម្បីផលប្រយោជន៍របស់គណបក្សកាន់អំណាច។

### ៥.២.២. តំណែងសម្រាប់សាច់ញាតិ ខ្សែស្រឡាយនិយម (Nepotism, Cronyism) និងទំនាស់ផលប្រយោជន៍ (Conflict of Interest)

តំណែងសម្រាប់សាច់ញាតិ ខ្សែស្រឡាយនិយម គឺជាករណីលម្អៀងផលប្រយោជន៍ ទៅសមាជិកនៃសាច់ញាតិ គ្រួសារ និងខ្សែស្រលាយដោយមន្ត្រីនយោបាយ ជាពិសេសការជួយជ្រោមជ្រែងលើកបន្តុប ឬតែងតាំង ឱ្យសមាជិកសាច់ញាតិ គ្រួសារ និងខ្សែស្រឡាយកាន់តំណែងក្នុងស្ថាប័នរបស់ខ្លួនដោយការជ្រើសរើសគ្មានតម្លាភាព។

តំណែងសម្រាប់សាច់ញាតិ ខ្សែស្រឡាយនិយម ត្រូវបានមើលឃើញថា កើតមាននៅស្ទើរតែ គ្រប់ក្រសួង ស្ថាប័ន នាយកដ្ឋាន និងមន្ទីរតាមបណ្តារាជធានី ខេត្តនានាក្នុងប្រទេសកម្ពុជា។ បើទោះបីជា កម្ពុជាមិនទាន់មានច្បាប់ប្រឆាំងនឹងអំពើបក្សពួកនិយម ខ្សែស្រឡាយសាច់ញាតិនិយម ឬគ្រួសារនិយមក៏ដោយ តែបើគិតពីអភិបាលកិច្ចល្អ ការប្រព្រឹត្តអំពើបក្សពួក ខ្សែស្រឡាយសាច់ញាតិ ឬគ្រួសារនិយម គឺជារឿងដែលមិនអាចទទួលយកបាន ហើយវាជាទំនាស់ផលប្រយោជន៍ មិនអាចពង្រឹងអភិបាលកិច្ចល្អនៃយុទ្ធសាស្ត្រស្នូលរបស់រដ្ឋាភិបាល ច្បាប់ប្រឆាំងអំពើពុករលួយ និងមិនស្របតាមកតិកាសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងអំពើពុករលួយផងដែរ។ ការប្រព្រឹត្តអំពើបក្សពួក ខ្សែស្រឡាយ សាច់ញាតិនិយម ឬគ្រួសារនិយមក្នុងស្ថាប័នអាចឈានទៅប្រព្រឹត្តអំពើពុករលួយបានយ៉ាងងាយ ដោយសារពួកគេមានឥទ្ធិពលទៅវិញទៅមក ហើយវាក៏ជាបញ្ហាប្រឈមយ៉ាងធំសម្រាប់ការប្រឆាំងអំពើពុករលួយ។

ការចាត់តាំង ឬការតែងតាំងជាលក្ខណៈបក្សពួក ខ្សែស្រឡាយសាច់ញាតិ ឬគ្រួសារនិយម ដោយគ្មានតម្លាភាព ដែលបានបិទឱកាស និងរារាំងការចូលរួមដោយពេញលេញ។ ករណីជាច្រើនកំពុងបានកើតមាននៅក្នុងគណបក្សនយោបាយ និងតាមស្ថាប័នរដ្ឋដោយគ្មានការត្រួតពិនិត្យ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែនក៏ធ្លាប់បានព្រមានដល់មន្ត្រីមិនឱ្យក្រសួង ឬស្ថាប័ននីមួយៗក្លាយជាទីកន្លែងសម្រាប់រៀបចំឱ្យមានបក្សពួក ខ្សែស្រឡាយ សាច់ញាតិ ឬគ្រួសារនិយម[5] និងថា

[5] http://khmer.voanews.com/archive/hello-voa/latest/2292/2687.html ហេឡូវីអូអេ, ការកាត់បន្ថយបញ្ហាគ្រួសារនិងបក្សពួកនិយមនៅកម្ពុជា, ថ្ងៃ១៤ ខែវិច្ឆិកា ឆ្នាំ២០១៤

ការងាររបស់ពួកគេមិនមែនជាជម្ងឺតពូជក៏ដោយ[6]។

ជាការពិត សាច់ញាតិ កូន ប្តី ប្រពន្ធនៃអ្នកនយោបាយ ឬសមាជិកគណបក្សនយោបាយត្រូវបានជាប់ឆ្នោត មិនមែនជាបញ្ហានោះទេ ប៉ុន្តែបញ្ហានៅត្រង់ថា របៀបដែលពួកគេក្លាយជាបេក្ខជនឈរឈ្មោះជាតំណាងរាស្ត្រតាមនីតិវិធីគ្មានតម្លាភាព។ នៅកម្ពុជាមេដឹកនាំគណបក្សជាអ្នកមានអំណាចសម្រេចតែងតាំងបេក្ខជន ដាក់ទៅក្នុងបញ្ជីបេក្ខជនរបស់គណបក្ស។ ក្រុមមេដឹកនាំគណបក្សសំខាន់ៗ បានដាក់ ឬជ្រើសរើសាច់ញាតិ កូន ប្តី ប្រពន្ធ របស់ខ្លួនឱ្យឈរជាបេក្ខជន។ ការជ្រើសរើសតែងតាំងនេះ គឺគ្មានតម្លាភាព ដែលឱ្យមានការប្រកួតប្រជែងក្នុងគណបក្សនោះឡើយ។ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣ កូនមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជាចំនួន១៤ករណី ត្រូវបានជ្រើសរើសឲ្យឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រសម្រាប់ការបោះឆ្នោត។ ជាឧទាហរណ៍ បេក្ខជនវ័យក្មេងទាំងនោះ មានលោក ហ៊ុន ម៉ានី អាយុ៣១ឆ្នាំ កូនប្រុសលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ឈរឈ្មោះនៅមណ្ឌលកំពង់ស្ពឺ។ លោក សុខ សូកាន អាយុ៣០ឆ្នាំ កូនប្រុសលោកឧបនាយករដ្ឋមន្ត្រី សុខ អាន ឈរឈ្មោះនៅខេត្តតាកែវ។ លោក ស សុខា អាយុ៣១ឆ្នាំ កូនប្រុសលោកឧបនាយករដ្ឋមន្ត្រី ស ខេង ឈរឈ្មោះនៅខេត្តព្រៃវែង លោក សាយ សំអាល់ អាយុ៣៤ ឆ្នាំ កូនប្រុសលោកសាយ ឈុំ អនុប្រធានព្រឹទ្ធសភា ឈរឈ្មោះនៅខេត្តកំពង់ចាម។ លោក ឌិត ទីណា កូនប្រុសរបស់ លោក ឌិត មន្ទី ប្រធានតុលាការកំពូលឈរឈ្មោះនៅខេត្តកណ្តាល លោក គឹម រិទ្ធី អាយុ ៣៣ ឆ្នាំ កូនប្រុសអគ្គមេបញ្ជាការរងកងយោពលខេមរភូមិន្ទលោក គន់ គីម ឈរឈ្មោះនៅខេត្ត កណ្តាល។ លោក ជាម ច័ន្ទសោភ័ណ អាយុ៤០ឆ្នាំ កូនប្រុសលោក ជាម យៀប ឈរឈ្មោះនៅខេត្តបាត់ដំបង និងលោក ឌី វិជ្ជា អាយុ ៣២ ឆ្នាំ ជាកូនប្រសារបស់លោក ហ៊ុន សែន ឈរឈ្មោះនៅខេត្តស្វាយរៀង។

ក៏មាន ៥ករណី នៃសាច់ញាតិ កូនរបស់ថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់របស់ថ្នាក់ដឹកនាំនៃគណបក្សសង្គ្រោះជាតិ ត្រូវបានជ្រើសតាំងឲ្យឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ អាណត្តិទី៤។ ជាឧទាហរណ៍ កន្លងមកដែរដូចជា លោក គង់ បូរ៉ា អាយុ៣៧ឆ្នាំ និងលោក គង់ សភា អាយុ ៣៨ ឆ្នាំ ជាកូនលោក គង់ គាំ សមាជិកព្រឹទ្ធសភា និងជាប្រធានគណបក្សសម រង្ស៊ី ដែលឱ្យឈរឈ្មោះនៅខេត្តព្រៃវែង និងស្វាយរៀង។ លើសពីនេះទៅទៀត ក៏មានបងប្អូនបង្កើត និងមានភរិយារបស់ថ្នាក់ដឹកនាំមួយចំនួននៃគណបក្សនយោបាយមួយនេះ ត្រូវបានជ្រើសតាំងឱ្យឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រនៅមណ្ឌលភ្នំពេញ និងមណ្ឌលសៀមរាបផងដែរ។

មានករណីជាច្រើនទាក់ទងនឹងការចាត់តាំង និងតែងតាំងសមាជិកគ្រួសារ សាច់ញាតិបង្កើត រួមទាំងប្តី ឬប្រពន្ធ ឬកូន ដើម្បីក្លាយជាមន្ត្រីសាធារណៈរបស់រដ្ឋក្នុងមុខតំណែងក្នុងស្ថាប័នរដ្ឋ។

[6] http://www.phnompenhpost.com/lift/nepotism-family-problem

ឧទាហរណ៍ករណីនៃស្ថាប័នរដ្ឋសភាជាតិ លោក ស៊ុន ឆ័យ តំណាងរាស្ត្រមណ្ឌលភ្នំពេញនៃគណបក្សសង្គ្រោះជាតិ និងជាអនុប្រធានគណៈកម្មការ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃរដ្ឋសភា បានស្នើឲ្យអគ្គលេខាធិការរដ្ឋសភា លោក ឡេង ប៉េងឡុង ផ្តល់បញ្ជីឈ្មោះបុគ្គលិកទាំងអស់នៃអគ្គលេខាធិការដ្ឋាននេះ រួមទាំងពន្យល់ពីការគ្រប់គ្រងបុគ្គលិក និងព័ត៌មានថា លោក មិត្ត ការ៉េន អគ្គលេខាធិការរងនៃរដ្ឋសភា ដែលធ្លាប់មានតួនាទីជាអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុបានតែងតាំងក្រុមគ្រួសារខ្លួនជាច្រើននាក់ រួមមាន កូនបង្កើត កូនប្រសា ប្អូនបង្កើត ប្អូនថ្លៃ និងក្មួយជាដើម ឲ្យបម្រើការក្នុងអគ្គនាយកដ្ឋានរបស់ខ្លួន[7]។

ជាការឆ្លើយតបទៅនឹងសំណើខាងលើ លោក ឈាង វុន អ្នកនាំពាក្យរដ្ឋសភា និងជាប្រធានគណៈកម្មការទី៩ នៃរដ្ឋសភា បានចាត់ទុកសំណុំរឿងគ្រួសារនិយម ដែលកំពុងធ្វើការ នៅក្នុងរដ្ឋសភារបស់លោក មិត្ត ការ៉េន អគ្គលេខាធិការរងរដ្ឋសភាជារឿងត្រឹមត្រូវតាមច្បាប់ ដោយលោកបានថ្លែងនៅក្នុងសន្និសីទកាសែតនាវិមានរដ្ឋសភាថា "ក្រុមគ្រួសារធ្វើការនៅក្នុងរដ្ឋសភាមិនជារឿងខុសច្បាប់នោះទេ ឲ្យតែពួកគេទាំងនោះមានសមត្ថភាព"[8]។

ឧទាហរណ៍ផ្សេងទៀត ករណីគ្រួសារ ខ្សែស្រឡាយ និងសាច់ញាតិនិយមក្នុងស្ថាប័នក្រសួងរបស់ខ្លួន ជាអ្នកមានអំណាចរដ្ឋមន្ត្រី ដែលតែងតាំងកូន ឬ/និងប្រពន្ធ និងសមាជិកក្រុមគ្រួសាររបស់ខ្លួន ត្រូវបានចាត់តាំង ឬតែងតាំងជាមន្ត្រីសាធារណៈរបស់រដ្ឋក្នុងមុខតំណែងស្ថិតនៅក្រោមការគ្រប់គ្រងស្ថាប័នរបស់ខ្លួន មានលោក សុខ អាន រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី លោក ហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេស លោក ចម ប្រសិទ្ធ អតីតរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលនៅពេលនេះត្រូវប្តូរទៅធ្វើជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លោក ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល លោក ជា ចាន់តូ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា លោកងួន ញ៉ិលអនុប្រធានទីពីរនៃរដ្ឋសភា ព្រមទាំងរដ្ឋមន្ត្រីនៅតាមបណ្តាក្រសួង មន្ទីរជាច្រើនផ្សេងទៀត សូម្បីតែលោក ឱម យ៉ិនទៀង ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ក៏មានកូនស្រីម្នាក់កាន់ការងារនៅក្រោមបង្គាប់របស់លោកដោយផ្ទាល់ផងដែរ[9]។

ជាមួយគ្នានេះ មានករណីជាច្រើនទាក់ទងនឹងវិសមិតភាពមន្ត្រីសាធារណៈរបស់រដ្ឋ ដែល

---

[7] ប៊ិច សុធារី and Kevin Ponniah, *សង្គ្រោះជាតិស្នើអគ្គលេខាធិការសភាពន្យល់ពីការគ្រប់គ្រងបុគ្គលិកដ៏ច្រើនសម្បើម* http://www.postkhmer.com/; Thu, 23 October 2014

[8] លោក ឈាង វុន ចេញមុខការពារ រឿងគ្រួសារនិយម ក្នុងរដ្ឋសភា, គេហទំព័រដើមអម្ពិល ថ្ងៃអង្គារ ទី១១ ខែវិច្ឆិកា ឆ្នាំ២០១៤

[9] ប៊ិច សុធារី and Kevin Ponniah, *សង្គ្រោះជាតិស្នើអគ្គលេខាធិការសភាពន្យល់ពីការគ្រប់គ្រងបុគ្គលិកដ៏ច្រើនសម្បើម* http://www.postkhmer.com/; Thu, 23 October 2014

មន្ត្រីសាធារណៈក្នុងតំណែង ជាពិសេសសមាជិករាជរដ្ឋាភិបាល កាន់កាប់ ឬគ្រប់គ្រងក្រុមហ៊ុនឯកជន ដែលករណី ឬសកម្មភាពទាំងនេះគឺជាការរំលោភបំពាន រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា ១២០ ដែលបានចែងថា "*មុខងារនៃសមាជិករាជរដ្ឋាភិបាលមានវិសមិតភាពនឹងសកម្មភាពខាងវិជ្ជាជីវៈផ្នែកពាណិជ្ជកម្ម ឬឧស្សាហកម្ម ហើយនឹងការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ*" និងផ្ទុយពីមាត្រា៣៥ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា "*ត្រូវហាមឃាត់ជាដាច់ខាតដល់អ្នករាជការនូវការចូលជាសមាជិកក្នុងក្រុមប្រឹក្សាភិបាល ឬគ្រប់គ្រងក្រុមហ៊ុនឯកជនដោយផ្ទាល់ឬដោយប្រយោល*"។ ឧទាហរណ៍ករណីចោទប្រកាន់ ស្តីពីវិសមិតភាពថាបានប្រព្រឹត្តផ្ទុយទៅនឹងមាត្រាខាងលើ ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិករាជ រដ្ឋាភិបាល និងជាក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យកម្ពុជាដែលជាសាកលវិទ្យាល័យឯកជនមួយ។ ចំណែកឯកឧត្តមកៅ គឹមហួន ជារដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ដែលជាសមាជិករាជរដ្ឋាភិបាល ហើយមានតួនាទីជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យកម្ពុជា។ សាកលវិទ្យាធិការនៃសាកលវិទ្យាល័យកម្ពុជាគឺជាស្ថាប័នឯកជនក៏ដូចជាផ្នែកនៃ*វិជ្ជាជីវៈផ្នែកពាណិជ្ជកម្ម*[10]។

បើតាមរបាយការណ៍ ស្តីពីការវាយតម្លៃប្រព័ន្ធសុចរិតភាពថ្នាក់ជាតិ ឆ្នាំ២០១៤ ដែលបានចេញផ្សាយកាលពីពេលថ្មីៗនេះ បានលើកឡើងថា បញ្ហាបក្ខពួកនិយម និងអំពើពុករលួយ មានការជាប់ទាក់ទងគ្នាយ៉ាងជ្រៅ ហើយបានរីករាលដាលក្នុងវិស័យសាធារណៈ និងតាមស្ថាប័នសំខាន់ៗរបស់រាជរដ្ឋាភិបាល ដែលបានធ្វើឲ្យមានភាពអន្តរាយដល់ប្រព័ន្ធនីតិរដ្ឋ ភាពស្មោះត្រង់ និងពេលខ្លះបានបង្អាក់កិច្ចខិតខំប្រឹងប្រែងរបស់អង្គភាពប្រឆាំងអំពើពុករលួយ។

## ៥.២.៣. ភាពមិនប្រក្រតីសំណូក និងការគិបគេងដោយមន្ត្រីនយោបាយ

នៅឆ្នាំ២០១៤ អង្គភាពប្រឆាំងអំពើពុករលួយបានប្រមូល ការប្រកាសទ្រព្យសម្បត្តិនៃមន្ត្រីនយោបាយ និងមន្ត្រីសាធារណៈក្នុងតំណែងបាន៩៩.៩% នៃចំនួន ៥២៥៥ រូប មន្ត្រីរាជការដែលជាប់កាតព្វកិច្ចត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលឆ្នាំ២០១៤ សម្រាប់របប២ឆ្នាំប្រកាសម្តង។ ជាការពិតមន្ត្រីមួយចំនួនបានប្រកាសទ្រព្យសម្បត្តិ ប៉ុន្តែការប្រកាសទ្រព្យសម្បត្តិគួរត្រូវបើកចំហរ ព្រោះថាពួកគេមានទ្រព្យ សម្បត្តិច្រើនគួរឱ្យសង្ស័យ ហើយអង្គភាពប្រឆាំងអំពើពុករលួយគួរអង្កេតអំពីទ្រព្យសម្បត្តិទាំងនោះ។ មន្ត្រីនយោបាយ និងមន្ត្រីក្នុងតំណែងជាច្រើនមានទ្រព្យសម្បត្តិច្រើនលើសលប់មិនធម្មតា។

មានការចោទប្រកាន់ និងទឡ្ហីករណ៍អំពីភាពមិនប្រក្រតីសំណូក និងការគិបគេងដោយមន្ត្រីនយោបាយ ដែលក្នុងនោះ ពាក់ព័ន្ធនឹងករណីគិបគេងថវិកា ការរំលោភដីធ្លី និងការបណ្តេញចេញ

[10] គេហទំព័រដើមត្នោត ថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១៥

ដោយបង្ខំ ភាពមិនប្រក្រតីក្នុងការដោះដូរទីតាំងក្រសួង មន្ទី ការិយាល័យសាធារណៈជាដើម។

ក្នុងឆ្នាំ២០១៤ ករណីដែលបន្តលេចធ្លោ ពាក់ព័ន្ធនឹងភាពមិនប្រក្រតីក្នុងការប្រើប្រាស់ធនធានជំនួយមិនត្រឹមត្រូវ គ្មានតម្លាភាព និងគណនេយ្យភាព គឺការប្រើប្រាស់ហិរញ្ញប្បទានដែលបានផ្តល់ដោយអង្គការមូលនិធិសកល (Global Fund) ដើម្បីប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍ របេង និងគ្រុនចាញ់ ។ នៅចុងឆ្នាំ២០១៣ អង្គការមូលនិធិសកល (Global Fund) បានរកឃើញការលួចបន្លំ និងការប្រាស់ថវិកាមិនត្រឹមត្រូវ ក្នុងជំនួយហិរញ្ញវត្ថុដែលផ្តល់ដោយមូលនិធិសកលដល់ប្រទេសកម្ពុជា ដើម្បីប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍ របេង និងជម្ងឺគ្រុនចាញ់។ របាយការណ៍បានកត់សម្គាល់ថា ក្នុងចំណោមទឹកប្រាក់ចំណាយ២២០,៣លានដុល្លារ ដែលការិយាល័យអធិការកិច្ចទូទៅរបស់អង្គការមូលនិធិសកល បានស្នើសុំត្រួតពិនិត្យនោះ មានតែឯកសារលើទឹកប្រាក់ចំណាយ៨៦,៩លានដុល្លារប៉ុណ្ណោះ[11]។

ជាឧទាហរណ៍ ករណីការចោទប្រកាន់ និងទឡ្ហីករណ៍ ចំពោះរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន ទទួលផែនអធិការកិច្ចគ្រប់គ្រងស្ថានីយថ្លឹងរថយន្ត និងបក្សពួកពាក់ព័ន្ធការកិបកេងប្រាក់ ដែលបានមកពីការផាកពិន័យរថយន្តដឹកជញ្ជូនលើសទម្ងន់នៅស្ថានីយ៍ថ្លឹងរថយន្តកូនដំរី ក្នុងខេត្តបន្ទាយមានជ័យ[12]។

ករណីជម្លោះដីធ្លីដ៏រាំរ៉ៃនៅតំបន់បឹងកក់ គឺជាបញ្ហាដែលលេចធ្លោ ក្នុងចំណោមករណីរំលោភបំពានដីធ្លី និងការបណ្តេញចេញនៃតំបន់ផ្សេងៗទៀតក្នុងរាជធានីភ្នំពេញ។ ប្រជាពលរដ្ឋជាង ២០០នាក់ មកពីសហគមន៍បឹងកក់ បុរីកីឡា ថ្មគោល និងសហគមន៍មួយចំនួនទៀត បានដាក់ពាក្យបណ្តឹងទៅអង្គភាពប្រឆាំងអំពើពុករលួយ ឲ្យបើកការស៊ើបអង្កេតអំពើពុករលួយទាក់ទងនឹងករណីនេះ។ អង្គភាពប្រឆាំងអំពើពុករលួយ បានអនុញ្ញាតឲ្យតំណាងអ្នកភូមិចំនួន៧នាក់ចូលជួប និងព្រមទទួលយកនូវពាក្យបណ្តឹងនោះ ប៉ុន្តែមិនទាន់មានការឆ្លើយតបណាមួយនៅឡើយទេ។[13] ផ្ទុយទៅវិញ តំណាងអ្នកភូមិបឹងកក់ចំនួន៧នាក់ ត្រូវបានចាប់ឃុំខ្លួន និងផ្តន្ទាទោស បន្ទាប់ពីបានតវ៉ានៅមុខសាលារាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៤ ពាក់ព័ន្ធនឹងបញ្ហាលូបង្ហូរទឹកស្អុយក្នុងមូលដ្ឋានរបស់ពួកគេ ដែលជាការទទួលខុសត្រូវរបស់អាជ្ញាធររាជធានីភ្នំពេញ[14]។

ភាពមិនប្រក្រតី ក្នុងការដោះដូរទីតាំងក្រសួងសុខាភិបាល និងការផ្តល់លុយគោល

---

[11] គេហទំព័រភ្នំពេញប៉ុស្តិ៍ ថ្ងៃទី ០៣ ខែមករា ឆ្នាំ២០១៤

[12] គេហទំព័រដើមអម្ពិល ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០១៤ និងគេហទំព័រឧត្តមគតិខ្មែរ ថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០១៤

[13] អ្នកភូមិបឹងកក់ដាក់ពាក្យបណ្តឹងទៅអង្គភាពប្រឆាំងអំពើពុករលួយ, វិទ្យុបារាំងអន្តរជាតិ (RFI),ផ្សាយថ្ងៃទី ៧ ខែកក្កដា ឆ្នាំ២០១៤

[14] សេចក្តីថ្លែងការណ៍រួមសង្គមស៊ីវិលថ្កោលទោសការចាប់ និងឃុំខ្លួនតំណាងសហគមន៍បឹងកក់ទាំងប្រាំពីរនាក់ ថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ២០១៤

នយោបាយដោយគ្មានច្បាប់ ដែលមានទីតាំងនៅវិថីកម្ពុជាក្រោមក្នុងសង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ ត្រូវដោះដូរទៅទីតាំងថ្មីក្នុងខណ្ឌទួលគោក ស្ថិតក្នុងបរិវេណវិទ្យាស្ថានជាតិសុខភាពសាធារណៈ ដែលការដោះដូរទីតាំងនេះ ត្រូវបានបែងចែកលុយពីការលក់ទ្រព្យសម្បត្តិសាធារណៈ។ បុគ្គលិកចំនួនជិត៦០០នាក់ បានបើកលុយគោលនយោបាយ ដោយប្រធាននាយកដ្ឋានទទួលបានក្នុងម្នាក់ៗ៣០០០ដុល្លារ អនុប្រធាននាយកដ្ឋានទទួលបាន២០០០ដុល្លារ ប្រធានការិយាល័យទទួលបាន១០០០ដុល្លារ អនុប្រធានការិយាល័យទទួលបាន៨០០ដុល្លារ និងបុគ្គលិកធម្មតាបាន៥០០ដុល្លារ ខណៈដែលថ្នាក់ដឹកនាំក្រសួងគិតពីរដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងអគ្គនាយក ព្រមទាំងអគ្គនាយករងនៃអគ្គនាយកដ្ឋាននានានៅក្នុងក្រសួងនេះ បានទទួលចំណែកយ៉ាងច្រើន[15]។

### ៥.២.៤.ភាពមិនប្រក្រតីសំណូក និងការកិបកេងដោយមន្ត្រីសាធារណៈក្នុងតំណែង

របាយការណ៍បានសន្មត់ថាស្ទើតែទាំងអស់នៃមន្ត្រីសាធារណៈក្នុងតំណែង ក៏ជាមន្ត្រីនយោបាយថ្នាក់ក្រោមរបស់គណបក្សកាន់អំណាច។ វាហាក់ជាប្រព័ន្ធទៅហើយដែលមន្ត្រីសាធារណៈរបស់រដ្ឋក្នុងតំណែងមានតួនាទីក្នុងរចនាសម្ព័ន្ធគណបក្ស ដែលអាចជាប្រធាន ឬថ្នាក់ដឹកនាំក្រុមការងារគណបក្សនៃអាជ្ញាធរមូលដ្ឋាន និងស្ថាប័នមន្ទីរ ឬការិយាល័យនីមួយៗ ឬសមាជិកក្រុមការងារចុះពង្រឹងមូលដ្ឋានគណបក្សជាដើម។ ពួកគេជាមន្ត្រីបក្ស និងធ្វើសកម្មភាពគណបក្សកាន់អំណាច។ មួយចំណែកលុយពីភាពមិនប្រក្រតី ត្រូវបានប្រើប្រាស់ដើម្បីបំពេញការងារ និងសកម្មភាពរបស់គណបក្ស ឬផ្តល់ទៅឲ្យគណបក្ស ព្រោះមន្ត្រីសាធារណៈរបស់រដ្ឋទាំងនោះមិនមានប្រាក់ខែគ្រប់គ្រាន់ ដើម្បីផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ របស់ពួកគេបានផង។

ក្នុងចំណោមទទ្បីករណ៍ និងការចោទប្រកាន់អំពីភាពមិនប្រក្រតីសំណូកដោយមន្ត្រីសាធារណៈក្នុងតំណែងមាន១៣១ករណី ក្នុងនោះករណីជាប់ពាក់ព័ន្ធជាមួយមន្ត្រីស៊ីវិលសាធារណៈក្នុងតំណែងមាន ៨៣ករណី ស្ថាប័នតុលាការ ៥ករណី កងកម្លាំងប្រដាប់អាវុធ ៣៨ ករណី និងអាជ្ញាធរមូលដ្ឋាន ៥ករណី។

[15] Cambodia Daily, 29 August, 2014

**ក្រាហ្វិក២. ប្រភេទមន្ត្រីសាធារណៈក្នុងតំណែងដែលត្រូវបានចោទប្រកាន់អំពីភាពមិនប្រក្រតីសំណូក**




មន្ត្រីស៊ីវិលសាធារណៈក្នុងតំណែង ត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តភាពមិនប្រក្រតីរួមមាន ប្រធាន អនុប្រធានមន្ទីរ ប្រធានការិយាល័យ និងអនុប្រធានការិយាល័យស្រុក។ ជាឧទាហរណ៍ ករណីចោទប្រកាន់លើប្រធានមន្ទីរសុរិយោដីថ្មីខេត្តព្រះសីហនុ ដែលបានស៊ីញ៉េចេញប្លង់កម្មសិទ្ធិដីសាធារណៈរបស់រដ្ឋមិនប្រក្រតីជាច្រើនដូចជា ដីតំបន់បឹងព្រៃកទប់បំពានលើសេចក្តីជូនដំណឹង (ស.ជ.ណ) និងលិខិតរបស់រដ្ឋមន្ត្រី អ៊ឹម ឈុនលឹម ព្រមទាំងដីចិញ្ចើមផ្លូវសាធារណៈសម្រាប់ធ្វើសួនច្បារ[16] និងករណីអំពើពុករលួយ លួចបន្លំថវិកាជាតិនៅក្នុងមន្ទីរអប់រំខេត្តតាកែវ ជាពិសេសពាក់ព័ន្ធជាមួយលោកប្រធានមន្ទីរអប់រំតែម្តង ហើយករណីនេះ ត្រូវបានស៊ើបអង្កេតដោយអង្គភាពប្រឆាំងអំពើពុករលួយ[17] ។

មន្ត្រីកងកម្លាំងប្រដាប់អាវុធ ក៏មានព័ត៌មានចោទប្រកាន់ទាក់ទងនឹងការគិបកេង និងភាពមិនប្រក្រតីសំណូកដែរ ឧទាហរណ៍ ករណីចោទប្រកាន់ និងចាប់ខ្លួនដោយអង្គភាពប្រឆាំងអំពើពុករលួយ លើមន្ត្រីនគរបាលក្រសួងមហាផ្ទៃម្នាក់ និងក្រសួងយុត្តិធម៌ម្នាក់ កាលពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៣ ជាប់ពាក់ព័ន្ធសំណូកជាប្រាក់ចំនួន២.៥០០ដុល្លារអាមេរិក។ ជនជាប់ចោទទាំង២នាក់ ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេល៣ឆ្នាំ តែអនុវត្តទោស២ឆ្នាំ នៅក្នុងពន្ធនាគារ និងបង្គាប់ឲ្យសងជម្ងឺចិត្តទៅជនរងគ្រោះ ដែលជាភាគីដើមបណ្តឹងម្នាក់ៗ ចំនួន ១២០០ដុល្លារអា

[16] គេហទំព័រដើមអម្ពិល ថ្ងៃច័ន្ទ ទី៥ ខែឧសភា ឆ្នាំ២០១៤

[17] គេហទំព័រដើម អម្ពិល ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៤

មេរិក[18]។

ក្រៅពីនេះ មន្ត្រីអាជ្ញាធរមូលដ្ឋាន មន្ត្រីបម្រើការនៅវិស័យជលផល និងព្រៃឈើដូចជា នាយខណ្ឌ/សង្កាត់រដ្ឋបាលជលផល និងព្រៃឈើ ក៏មានជាប់ពាក់ព័ន្ធនឹងអំពើភាពមិនប្រក្រតី សំណូក ក្នុងពេលបំពេញតួនាទីភារកិច្ចរបស់ខ្លួនដែរដូចជាករណីពាក់ព័ន្ធនឹងបទកំហែងយករបស់ នាយសង្កាត់ និងនាយរងសង្កាត់រដ្ឋបាលព្រៃឈើជ្រោយបន្ទាយ។ មន្ត្រីទាំងពីរនាក់នេះ ត្រូវបាន ត្រូវបានចាប់ខ្លួនបញ្ជូនទៅអង្គភាពប្រឆាំងអំពើពុលរលួយ[19]។

មានករណីចោទប្រកាន់ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ និងក្រឡាបញ្ជីនៃ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ពីបទដេញថ្លៃមិនត្រឹមត្រូវ និងបទស៊ីសំណូកដែលជាប់ ពាក់ព័ន្ធនិងករណីដេញថ្លៃលក់ដោយបង្ខំនូវដី-ផ្ទះមួយកន្លែងក្នុងសង្កាត់បឹងកក់២ ខណ្ឌទួលគោគ រាជធានីភ្នំពេញ[20]។




ក្នុងចំណោមករណីនៃអំពើពុករលួយពាក់ព័ន្ធជាមួយមន្ត្រីសាធារណៈក្នុងតំណែង មាន៦ ករណី បានចាត់វិធានការ តាមរយៈកសាងសំណុំរឿងបញ្ជូនទៅតុលាការ១៣ករណី កំពុងស៊ើប អង្កេត និងមាន១៣ ករណីផ្សេងទៀត បានចាត់វិធានការដោយអង្គភាពប្រឆាំងអំពើពុករលួយ (អ. ប.ព)។

[18] កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃច័ន្ទ ទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤

[19] កាសែតកោះសន្តិភាពចុះផ្សាយកាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៤

[20] គេហទំព័រដើម អម្ពិល ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៤

## ៥.៣. គ្មានតម្លាភាពនៃទ្រព្យសម្បត្តិ និងហិរញ្ញវត្ថុរបស់គណបក្សសំខាន់ៗ

គ្មានព័ត៌មាន ឬរបាយការណ៍អំពីទ្រព្យសម្បត្តិ និងហិរញ្ញវត្ថុរបស់គណបក្សនយោបាយ ជាពិសេសគណបក្សកាន់អំណាច។ មិនថាសាធារណៈជនទេ សូម្បីតែសមាជិករបស់គណបក្ស មិនដែលបានទទួលរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឡើយ។ របៀបវារៈនៃកិច្ចប្រជុំ និងសន្និបាតរបស់គណបក្សពុំដែលបានលើកឡើងពីការធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ឬបច្ចុប្បន្ន ភាពស្ថានភាពហិរញ្ញវត្ថុគណបក្ស។ គណបក្សបានយកលេសថាបានធ្វើរបាយការណ៍ប្រចាំឆ្នាំទៅក្រសួងមហាផ្ទៃ ឬក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ គណបក្សនយោបាយខ្លះ ជាពិសេសគណបក្សកាន់អំណាចបានលក់ និងជួលអាគារ/ស្នាក់ការគណបក្ស។

ជាការពិត វាមានគណបក្សនយោបាយមួយចំនួនបានចែកចាយរបាយការណ៍ហិរញ្ញវត្ថុដល់សាធារណៈជនក្នុងអំឡុងពេលយុទ្ធនាការបោះឆ្នោត និងតាមព្រឹត្តិការណ៍ជាក់លាក់។ កន្លងមកគណបក្សសង្គ្រោះជាតិបានរាយការណ៍ពីចំណូល ចំណាយដែលបានមកពីការរៃអង្គាស សម្រាប់ព្រឹត្តការណ៍មួយៗ ដូចជាក្នុងកំឡុងពេលធ្វើបាតុកម្មជាដើម។

ទោះបីជាយ៉ាងនេះក្តី កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ក៏មានបញ្ហាមួយនៃហិរញ្ញវត្ថុគណបក្ស ដោយមន្ត្រីជាន់ខ្ពស់មួយរូបនៃគណបក្សសង្គ្រោះជាតិ បានចោទប្រកាន់ថ្នាក់ដឹកនាំរបស់ខ្លួនពាក់ព័ន្ធនឹងភាពមិនប្រក្រតីអំពីហិរញ្ញវត្ថុ និងសំណូក។ ប៉ុន្តែអ្នកនាំពាក្យគណបក្សសង្គ្រោះជាតិបានបដិសេធថាជារឿងប្រឌិត។ គណៈកម្មាធិការវិន័យគណបក្សសង្គ្រោះជាតិ បានកោះប្រជុំជាបន្ទាន់មួយ នៅរសៀលថ្ងៃអាទិត្យ ទី២៨ ខែធ្នូ ឆ្នាំ២០១៤ នេះ ដើម្បីធ្វើការប្រជុំដាក់វិន័យដកលើលលោកស្រី ឡាក់ សុភាព ពីសមាជិកគណៈកម្មការនាយក ដែលជាជំនួយការលោក កឹម សុខា អនុប្រធានគណបក្សសង្គ្រោះជាតិ និងជាអនុប្រធានទី១ នៃរដ្ឋសភា[21]។

របាយការណ៍សង្កេតរបស់ខុមហ្វ្រែល ពីការចំណាយរបស់គណបក្សនយោបាយក្នុង សកម្មភាពនៃការឃោសនាបោះឆ្នោតកាលពីឆ្នាំ២០១៣ កន្លងមក (មិនរួមបញ្ចូលតម្លៃចំណាយលើប្រព័ន្ធផ្សព្វផ្សាយ ការផ្តល់ជាអំណោយ និងការទិញសន្លឹកឆ្នោត) បានរកឃើញថា គណបក្សប្រជាជនកម្ពុជា បានចំណាយជាមធ្យម ១៥,០០០,០០០ ដុល្លារសហរដ្ឋអាមេរិកសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតទូទាំងប្រទេស។ ចំណែកគណបក្សសង្គ្រោះជាតិចំណាយប្រមាណ ៣,៥០០,០០០ ដុល្លាសហរដ្ឋអាមេរិក ខណៈដែលគណបក្សហ្វ៊ុនស៊ិនប៉ិចចំណាយប្រមាណ ៥០០,០០០ ដុល្លារសហរដ្ឋអាមេរិក[22]។

---

[21] គេហទំព័រ Cambodia Express News (CEN) ភ្នំពេញ. ថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១៤

ក្រោយពីបានសង្កេតទៅលើការចំណាយក្នុងយុទ្ធនាការបោះឆ្នោត ខុមហ្វ្រែល បានសង្កេតថែមទៀត លើការបន្តផ្តល់ប្រាក់កាសរបស់បុគ្គលឯកជនសម្រាប់ជាអំណោយ ឬការកសាងហេដ្ឋរចនាសម្ព័ន្ធ ដោយមេដឹកនាំគណបក្សកាន់អំណាច ខណៈដែលករណីទាំងនេះក្លាយជាការទិញសន្លឹកឆ្នោតក្នុងយុទ្ធនាការបោះឆ្នោត។

## ៦. សន្និដ្ឋាន និងអនុសាសន៍

ការសង្កេតក្នុងកំឡុងពីមករា ដល់ខែវិច្ឆិកា ឆ្នាំរកឃើញយ៉ាងហោចណាស់មាន ២១៧ ករណីពុករលួយទាក់ទិននយោបាយ។ ភាពមិនប្រក្រតីសំណូកដោយមន្ត្រីសាធារណៈក្នុងតំណែងគឺមាន១៣១ករណី ខណៈដែលករណីជាបញ្ហាដែលពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវមាន៦០ករណី ហើយករណីរំលោភអំណាចមាន៣ករណី ករណីពាក់ព័ន្ធនឹងបញ្ហាខ្សែស្រឡាយ សាច់ញាតិនិយមមាន១៨ករណី និងភាពមិនប្រក្រតីសំណូកដោយមន្ត្រីនយោបាយមាន៥ករណី។

មានការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ បម្រើឱ្យគណបក្សនយោបាយចំនួន៦០ករណីបានកត់ត្រាខាងលើក្នុងនោះ គឺជាករណីនៃការប្រើប្រាស់ធនធានមនុស្សរបស់រដ្ឋ ដូចជាការចូលរួមពីសំណាក់កងកម្លាំងប្រដាប់អាវុធ និងមន្ត្រីរាជការស៊ីវិល និងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ក្នុងការធ្វើសកម្មប្រឆាំង ឬគាំទ្រចំពោះគណបក្សនយោបាយ និងថ្នាក់ដឹកនាំគណបក្សផ្សេង។

ចំនួនករណីនៃភាពមិនប្រក្រតីនៃការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ ក្នុងឆ្នាំ២០១៤នេះ គឺមានការធ្លាក់ចុះ បើប្រៀបធៀបនឹងអំឡុងពេលឃោសនាបោះឆ្នោត ពីខែកញ្ញា ដល់ខែកក្កដា ឆ្នាំ២០១៣កន្លងមក ដែលមាន៣៤៣ ករណី។ ករណីខាងលើកើតមាននៅ១០រាជធានី ខេត្ត ដោយឡែកនៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តកំពង់ធំ មានករណីប្រើប្រាស់ធនធានមនុស្សរបស់រដ្ឋ បម្រើឱ្យគណបក្សនយោបាយច្រើនជាងគេ បើប្រៀបធៀបជាមួយខេត្តផ្សេងទៀត។

ប្រព័ន្ធផ្សព្វផ្សាយរដ្ឋ ដោយឡែកទូរទស្សន៍ជាតិកម្ពុជា (ទទក) ត្រូវបានប្រើប្រាស់ដើម្បីគាំទ្រ និងឃោសនាឱ្យគណបក្សប្រជាជនកម្ពុជា ឬឃោសនាវិះគន់ប្រឆាំងគណបក្សផ្សេង និងនៅតែ

បន្តភាពលំអៀងក្នុងការផ្សព្វផ្សាយរបស់ខ្លួន[23]។ នៅឆ្នាំ២០១៤ ចំនួនប្រហែល៩០នៃព័ត៌មានដែលបានសង្កេត គឺបានផ្សព្វផ្សាយសកម្មភាពរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលដែលគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា ហើយ ៧៥% នៃខ្លឹមសារនៃសកម្មភាពទាំងនោះគឺនិយាយគាំទ្រ និងចំណុចល្អរបស់រដ្ឋាភិបាល និងគណបក្សកាន់អំណាច និងមាន២៥% រិះគន់ ឬប្រឆាំងទៅនឹងគណបក្សផ្សេង ជាពិសេសគណបក្សសង្គ្រោះជាតិ។

ស្ថានភាពតម្លាភាពនៃការគ្រប់គ្រងថវិកានៅកម្ពុជា គឺនៅមានកម្រិតទាបជាខ្លាំងនៅឡើយ។ រាជរដ្ឋាភិបាលកម្ពុជាមិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់ដល់សាធារណជន និងសមាជិកសភា អំពីថវិកាជាតិ និងសកម្មភាពហិរញ្ញវត្ថុរបស់ខ្លួននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ កត្តានេះបង្កការលំបាកដល់ប្រជាពលរដ្ឋ និងរដ្ឋសភាក្នុងការតាមដានការចាយវាយរបស់រាជរដ្ឋាភិបាល និងការទាមទារឱ្យរាជរដ្ឋាភិបាលទទួលខុសត្រូវ ចំពោះការគ្រប់គ្រងប្រាក់កាសសាធារណៈរបស់ខ្លួនដែលរួមមាន ការប្រមូលចំណូល និងការប្រើប្រាស់មូលនិធិសាធារណៈនានាប្រកបដោយប្រសិទ្ធភាព។

ករណីគ្មានតម្លាភាពមួយ គឺការគ្រប់គ្រងចំណូលនៃថវិកាជាតិ ដែលបានពីការប្រមូលចំណូលពីការលក់ ការដូរ ឬជួលទ្រព្យសម្បត្តិរបស់រដ្ឋ រាជរដ្ឋាភិបាលកម្ពុជាក៏មិនបាន ផ្តល់ព័ត៌មានគ្រប់គ្រាន់ ឬរបាយការណ៍ និងការពន្យល់ច្បាស់លាស់ដល់សាធារណជនដែរ។

មានករណីរំលោភអំណាចមួយចំនួន ដោយរដ្ឋាភិបាល និងអាជ្ញាធរ ដើម្បីបំរើផលប្រយោជន៍នយោបាយ ក្នុងនោះមានការចេញលិខិត បទបញ្ជាដែលលើសពីច្បាប់កំណត់ ឬគ្មានច្បាប់ចែង។ ជាឧទាហរណ៍ ការចេញសារាចរណែនាំ ស្តីពីបែបបទការងាររបស់គណៈកម្មការនានានៃរដ្ឋសភា ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ ដោយប្រធានរដ្ឋសភា។

ជាការពិត សាច់ញាតិ កូន ប្តី ប្រពន្ធនៃអ្នកនយោបាយ ឬសមាជិកគណបក្សនយោបាយត្រូវបានជាប់ឆ្នោត មិនមែនជាបញ្ហានោះទេ ប៉ុន្តែបញ្ហានៅត្រង់ថា របៀបដែលពួកគេក្លាយជាបេក្ខជនឈរឈ្មោះជាតំណាងរាស្ត្រតាមនីតិវិធីគ្មានតម្លាភាព។ នៅកម្ពុជាមេដឹកនាំគណបក្សជាអ្នកសម្រេចតែងតាំងបេក្ខជន ដាក់ទៅក្នុងបញ្ជីបេក្ខជនរបស់គណបក្ស។ ក្រុមមេដឹកនាំគណបក្សសំខាន់ៗ បានដាក់ ឬតែងតាំងសាច់ញាតិ កូន ប្តី ប្រពន្ធ របស់ខ្លួនឱ្យឈរជាបេក្ខជន។ ការជ្រើសរើសតែងតាំងនេះ គឺគ្មានតម្លាភាព ដែលឱ្យមានការប្រកួតប្រជែងក្នុងគណបក្សនោះឡើយ។ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣ កូនមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជាចំនួន

[23] របាយការណ៍ខុមហ្វ្រែល៖ ប្រជាធិបតេយ្យ ការបោះឆ្នោត និងកំណែទម្រង់ ២០១១ ភ្នំពេញ ខែមីនា ឆ្នាំ២០១២។

១៤ ករណី ត្រូវបានជ្រើសរើសឲ្យឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រសម្រាប់ការបោះឆ្នោត។

ក៏មាន ៥ ករណីនៃសាច់ញាតិ កូនរបស់ថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់របស់ថ្នាក់ដឹកនាំនៃគណបក្សសង្គ្រោះជាតិ ត្រូវបានជ្រើសតាំងឲ្យឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ អាណត្តិទី៥។ មានករណីជាច្រើនទាក់ទងនឹងការចាត់តាំង និងតែងតាំងសមាជិកគ្រួសារ សាច់ញាតិ បង្កើត រួមទាំងប្ដី ឬប្រពន្ធដើម្បីក្លាយជាមន្ត្រីសាធារណៈរបស់រដ្ឋក្នុងមុខតំណែងក្នុងស្ថាប័នរដ្ឋ។

ក្នុងចំណោមទទ្បីករណ៍ និងការចោទប្រកាន់អំពីភាពមិនប្រក្រតីសំណូកដោយមន្ត្រីសាធារណៈក្នុងតំណែងមាន១៣១ករណី ក្នុងនោះករណីជាប់ពាក់ព័ន្ធជាមួយមន្ត្រីសាធារណៈក្នុងតំណែងមាន ៨៣ករណី ស្ថាប័នតុលាការ ៥ករណី កងកម្លាំងប្រដាប់អាវុធ ៣៨ ករណី និងអាជ្ញាធរមូលដ្ឋាន ៥ករណី។ ក្នុងចំណោមករណីនៃអំពើពុករលួយពាក់ព័ន្ធជាមួយមន្ត្រីសាធារណៈក្នុងតំណែងបំរើផលប្រយោជន៍នយោបាយ មាន៤% ត្រូវបានចាត់វិធានការ តាមរយៈកសាងសំណុំរឿងបញ្ជូនទៅតុលាការ១០%កំពុងស៊ើបអង្កេត និងមាន១០%ផ្សេងទៀត បានចាត់វិធានការដោយអង្គភាពប្រឆាំងអំពើពុករលួយ (អ.ប.ព)។

**អនុសាសន៍មួយចំនួន ៖**

១.អនុម័តច្បាប់ ស្តីពីសិទ្ធិទទួលបានព័ត៌មាន ដើម្បីធានាឲ្យមានការបើកចំហព័ត៌មានជាអតិបរមា និងអនុញ្ញាតឲ្យសាធារណជនទទួលបានព័ត៌មានផ្លូវការ និងធានាថា ច្បាប់នេះត្រូវអនុវត្តចំពោះជនគ្រប់រូប ដោយគ្មានការរើសអើង ហើយព័ត៌មានត្រូវផ្តល់ជូនតាមសំណើ ដោយឥតគិតថ្លៃ ឬតម្លៃទាប។

២.បង្កើតច្បាប់ស្តីពីហិរញ្ញវត្ថុគណបក្សនយោបាយ និងបញ្ញត្តិស្តីពីហរិញ្ញវត្ថុរបស់គណបក្សយុទ្ធនាការឃោសនាបោះឆ្នោត

៣. ការធ្វើវិសោធនកម្មមាត្រាមួយចំនួន ក្នុងច្បាប់ប្រឆាំងអំពើពុករលួយដូចខាងក្រោម៖

- ដាក់កំហិតទៅលើបក្សពួកនិយម និងខ្សែស្រឡាយនិយម និងទំនាស់ផលប្រយោជន៍ក្នុងរដ្ឋាភិបាល និងស្ថាប័នរដ្ឋដទៃទៀត។
- បង្ហាញជាសាធារណៈ ការប្រកាសទ្រព្យសម្បត្តិរបស់សមាជិករដ្ឋាភិបាល និងសមាជិកសភាជាតិ។

៤. បង្កើតបញ្ញាត្តិស្តីពីការកំណត់ចំនួនរដ្ឋាភិបាល និងទីប្រឹក្សារបស់រដ្ឋាភិបាល ទីប្រឹក្សារបស់នាយករដ្ឋមន្ត្រី និងរបស់ថ្នាក់ដឹកនាំសភា។

៥. បង្កើតយន្តការណ៍ របស់រដ្ឋសភាក្នុងការសួរដេញដោល អំពីការរំលោភអំណាច។